បោះពុម្ពលើកទី ៧



# ការណែនាំបំភ្លឺអំពី
# ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម

# មាតិកា


សំណួរទី ១ : ហេតុអ្វីបានជាប្រើរយៈពេលយូរម្លេះទើបចាប់ផ្តើមជំនុំជម្រះក្តីអ្នកដែលត្រូវបានចោទប្រកាន់ថា បានទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ? ........ ៨

សំណួរទី ២ : ហេតុអ្វីបានជាយើងទើបតែជំនុំជម្រះក្តីនៅពេលនេះ ? តើការជំនុំជម្រះក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នឹងផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជនកម្ពុជា ? ........ ៨

សំណួរទី ៣ : តើនរណាខ្លះនឹងត្រូវនាំយកមកជំនុំជម្រះក្តី ? ........ ៩

សំណួរទី ៤ : តើជនសង្ស័យនឹងទទួលទោសយ៉ាងដូចម្តេច ប្រសិនបើតុលាការរកឃើញថាគាត់មានទោស ? ........ ១០

សំណួរទី ៥ : តើមានការលើកលែងទោស ឬការអនុគ្រោះទោសដែរឬទេ ? ........ ១០

សំណួរទី ៦ : តើធ្លាប់មានមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណាម្នាក់ត្រូវបានជំនុំជម្រះក្តីពីមុនមកដែរឬទេ ? ........ ១១

សំណួរទី ៧ : តើបណ្តាប្រទេសដែលធ្លាប់បានគាំទ្រ ឬក៏ជាប់ពាក់ព័ន្ធជាមួយកម្ពុជាប្រជាធិបតេយ្យឬក៏បណ្តាប្រទេសដែល បានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមនៅកម្ពុជាមុនឆ្នាំ១៩៧៥ នឹងត្រូវជំនុំជម្រះដែរឬទេ ? ........ ១១

សំណួរទី ៨ : តើនឹងមានការជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តដោយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ឬអ្នកដទៃទៀតក្រោយឆ្នាំ១៩៧៩ ដែរឬទេ ? ........ ១២

សំណួរទី ៩ : តើមានសំណុំរឿងប៉ុន្មានកំពុងដំណើរការនៅចំពោះមុខ អ.វ.ត.ក ? ........ ១២

សំណួរទី ១០ : តើការជំនុំជម្រះក្តីនឹងប្រើរយៈពេលប៉ុន្មានឆ្នាំ ? ........ ១៤

សំណួរទី ១១ : តើការជំនុំជម្រះក្តីនេះកំពុងប្រព្រឹត្តទៅនៅកន្លែងណា ? ........ ១៥

សំណួរទី ១២ : តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការរបៀបដូចម្តេច ? ........ ១៥

សំណួរទី ១៣ : តើនរណាខ្លះអាចចូលទៅស្តាប់ការជំនុំជម្រះក្តីបាន ? ........ ១៥

សំណួរទី ១៤ : ប្រសិនបើយើងមិនអាចចូលមើលសវនាការនេះបាន តើធ្វើដូចម្តេចយើងអាចដឹងបានពីអ្វីដែលកំពុងកើតឡើងនៅក្នុងតុលាការ ? ........ ១៧

សំណួរទី ១៥ : តើចៅក្រមត្រូវតែងតាំងឡើងយ៉ាងដូចម្តេច ? ........ ១៧

សំណួរទី ១៦ : តើចៅក្រមនឹងឈានដល់ការចេញសេចក្តីសម្រេចយ៉ាងដូចម្តេច ? ........ ១៨

សំណួរទី ១៧ : តើនរណាជាអ្នកសម្រេចថានរណាខ្លះនឹងត្រូវប្រឈមមុខនឹងការជំនុំជម្រះក្តី ហើយពួកគេនឹងត្រូវចោទប្រកាន់ពីបទល្មើសអ្វី ? ........ ១៨

សំណួរទី ១៨ : តើមានអ្វីកើតឡើង ប្រសិនបើសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេតមិនយល់ស្រប គ្នាថាតើត្រូវបញ្ជូន ឬមិនបញ្ជូនរឿងក្តីទៅជំនុំជម្រះនោះ ? ........ ១៨


រូបថតក្របមុខៈ រូបថតសាលសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា          រូបថតៈ ញ៉ែត សុខហេង

សំណួរទី ១៩ : តើចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងធ្វើការងារអ្វីខ្លះ? ..... ១៩

សំណួរទី ២០ : តើភស្តុតាងអ្វីខ្លះនឹងត្រូវប្រើប្រាស់នៅពេលជំនុំជម្រះក្តី? ..... ១៩

សំណួរទី ២១ : តើបទឧក្រិដ្ឋអ្វីនឹងត្រូវលើកយកមកជំនុំជម្រះ? តើការជំនុំជម្រះប្រើច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិ? ..... ២០

សំណួរទី ២២ : តើចុងចោទមានសិទ្ធិអ្វីខ្លះ? ..... ២១

សំណួរទី ២៣ : តើនរណាខ្លះនឹងត្រូវកោះអញ្ជើញឱ្យធ្វើជាសាក្សី? ..... ២២

សំណួរទី ២៤ : តើខ្ញុំត្រូវផ្តល់ព័ត៌មានទៅឱ្យតុលាការដែរឬទេ? ..... ២២

សំណួរទី ២៥ : តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេច ប្រសិនបើខ្ញុំចង់ផ្តល់ព័ត៌មានអំពីនរណាម្នាក់ដែលខ្ញុំជឿជាក់ថាបានប្រព្រឹត្ត បទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរក្នុងអំឡុងរបបខ្មែរក្រហម? ..... ២២

សំណួរទី ២៦ : តើការគាំទ្រអ្វីខ្លះនឹងត្រូវផ្តល់ទៅឱ្យសាក្សី និងជនរងគ្រោះដែលផ្តល់សក្ខីកម្ម និងសម្រាប់មនុស្សទូទាំងប្រទេស ដែលអាចនឹងមានការឈឺចាប់ក្នុងចិត្តនៅពេលស្តាប់ឮសក្ខីកម្មដែលបានបង្ហាញនៅក្នុងតុលាការ? ..... ២៣

សំណួរទី ២៧ : តើជនរងគ្រោះអាចចូលរួមក្នុងដំណើរការជំនុំជម្រះក្តីតាមវិធីណា? ..... ២៣

សំណួរទី ២៨ : តើជនរងគ្រោះមានសិទ្ធិទទួលបានសំណងដែរឬទេ? ..... ២៤

សំណួរទី ២៩ : ហេតុអ្វីបានជាអង្គការសហប្រជាជាតិចូលរួមក្នុងដំណើរការជំនុំជម្រះក្តីនេះ? ..... ២៦

សំណួរទី ៣០ : ហេតុអ្វីបានជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមិនត្រូវបានយកទៅជំនុំជម្រះក្តីនៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិ(ICC) នៅទីក្រុងឡាអេ ឬនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ(ICJ)? ..... ២៦

សំណួរទី ៣១ : តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាតុលាការកម្ពុជាឬជាតុលាការអន្តរជាតិ? ..... ២៦

សំណួរទី ៣២ : តើមានតុលាការផ្សេងទៀតនៅក្នុងពិភពលោកដែលមានលក្ខណៈដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ? ..... ២៧

សំណួរទី ៣៣ : ហេតុអ្វីបានជាតុលាការប្រភេទនេះត្រូវបានយកមកប្រើសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា? ..... ២៧

សំណួរទី ៣៤ : តើដំណើរការជំនុំជម្រះក្តីនេះត្រូវចំណាយថវិកាប៉ុន្មាន? ..... ២៧

សំណួរទី ៣៥ : តើតុលាការនេះទទួលថវិកាមកពីប្រភពណាខ្លះ? ..... ២៨

សំណួរទី ៣៦ : តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពីរឿងខ្មែរក្រហមនិងដំណើរការជំនុំជម្រះក្តីទាំងនេះដោយវិធីណា? ..... ២៨

សំណួរទី ៣៧ : តើអង្គការក្រៅរដ្ឋាភិបាលមានតួនាទីអ្វីខ្លះ? ..... ២៩

សំណួរទី ៣៨ : តើខ្ញុំអាចស្វែងរកសេវាគាំទ្រសម្រាប់រូបខ្ញុំនៅទីណា? ..... ២៩

# អារម្ភកថា



ដោយសម្តេចអគ្គមហាសេនាបតី
តេជោ ហ៊ុន សែន
*នាយករដ្ឋមន្ត្រី*
*នៃព្រះរាជាណាចក្រកម្ពុជា*

## បងប្អូនរួមជាតិជាទីស្នេហា!

គ្មានប្រជាជនកម្ពុជាណាម្នាក់បានគេចផុតពីការបំផ្លិចបំផ្លាញ ដែលប្រព្រឹត្តមកលើមាតុភូមិជាទីស្នេហារបស់យើង ក្នុងអំឡុងពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ ដែលខ្មែរក្រហមកាន់អំណាចនៅក្នុងរបបមួយដែលគេស្គាល់ឈ្មោះថា កម្ពុជាប្រជាធិបតេយ្យ នោះទេ។

ក្នុងអំឡុងពេលនោះ ប្រជាជនកម្ពុជាជាង ៣លាននាក់ បានបាត់បង់ជីវិត។ អ្នកទាំងនោះគឺជាឪពុក ម្តាយ កូន សាច់ញាតិ មិត្តរួមការងារ( សហសេវិក ) និងមិត្តភ័ក្តិរបស់យើង។ យើងទាំងអស់គ្នាដែលនៅសល់ពីស្លាប់ បានរស់នៅអស់រយៈពេលជាង ២៥ឆ្នាំ ដោយក្តីឈឺចាប់ខ្លោចផ្សា សោកសង្រេងដល់អ្នកដែលបានបាត់បង់ជីវិតទៅហើយ និងសុបិនអាក្រក់នៃអនុស្សាវរីយ៍ដ៏ជូរចត់របស់យើងតាមលងឥតស្រាកស្រាន្ត។

សូម្បីតែបងប្អូនរួមជាតិដែលកើតក្រោយឆ្នាំ១៩៧៩ ដែលមិនបានជួបប្រទះផ្ទាល់នូវឧក្រិដ្ឋកម្មទាំងនោះក៏ទទួលរងនូវបន្ទុកដ៏ធ្ងន់ធ្ងរដែរ។ បងប្អូនឃើញពុកម៉ែ និងសាច់ញាតិប្រុសស្រីរបស់បងប្អូនកំពុងឈឺចាប់ខ្លោចផ្សានៅឡើយ។ បងប្អូនក៏រួមចំណែកផងដែរនូវរាល់ការលំបាកក្នុងការកសាងសង្គមជាតិយើងឡើងវិញពីបាតដៃទទេឬឆ្នាំសូន្យ ដោយមិនបានទទួលអត្ថប្រយោជន៍នៃគតិបណ្ឌិត និងបទពិសោធន៍ពីញាតិមិត្តដែលបានស្លាប់ទៅហើយនោះទេ។

យើងបាននិងកំពុងតស៊ូយ៉ាងខ្លាំងក្លាដើម្បីស្តារប្រទេសជាតិឡើងវិញហើយយើងទាំងអស់គ្នាដឹងថាកម្ពុជាសព្វថ្ងៃនេះមានលក្ខណៈអន់ថយឆ្ងាយជាងបណ្តាប្រទេសជិតខាងក្នុងវិស័យសុខាភិបាល អប់រំ និងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច។

ឥឡូវនេះ ពេលវេលាបានមកដល់ហើយសម្រាប់នាំយកអ្នកទាំងឡាយណាដែលទទួលខុសត្រូវក្នុងការរៀបចំផែនការ និងបញ្ជាឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មព្រៃផ្សៃ ឱ្យមកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត។ ដោយអនុលោមទៅតាមការចរចាជាមួយអង្គការសហប្រជាជាតិ អស់រយៈពេលជាច្រើនឆ្នាំ តុលាការថ្មីមួយត្រូវបានបង្កើតឡើងដោយមានបញ្ចូលមន្ត្រីបម្រើការងារនិងចៅក្រមអន្តរជាតិ។ ឈ្មោះជាផ្លូវការរបស់តុលាការនេះគឺ *អង្គជំនុំ*

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ នេះគឺជាតុលាការដំបូងនៅក្នុងពិភពលោកដែលជំនុំជម្រះក្តីបែបនេះ។

ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ មិនត្រឹមតែត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនកម្ពុជាប៉ុណ្ណោះទេ ថែមទាំងប្រឆាំងនឹងមនុស្សជាតិទាំងមូលផងដែរ។ ដូចនេះ វាសមស្របណាស់ដែលពលរដ្ឋកម្ពុជាត្រូវសហការជាមួយសហគមន៍អន្តរជាតិ ដើម្បីជំនុំជម្រះទោសជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ហើយការធ្វើដូច្នេះនឹងជួយបង្កើតនូវវប្បធម៌មួយដែលទប់ស្កាត់មិនឱ្យមានការកើតឡើងសាជាថ្មីនៃឧក្រិដ្ឋកម្មបែបនេះនៅគ្រប់ទិសទីនៃពិភពលោក។ យើងសង្ឃឹមថា តុលាការថ្មីរបស់យើងនឹងក្លាយទៅជាតុលាការគំរូដ៏ជោគជ័យដែលមិនមែនសម្រាប់តែកម្ពុជាប៉ុណ្ណោះទេ គឺថែមទាំងផ្តល់វិភាគទានដ៏ទូលំទូលាយដល់ប្រព័ន្ធយុត្តិធម៌ពិភពលោកផងដែរ។

ខ្ញុំមានជំនឿថា បងប្អូនរួមជាតិនឹងចូលរួមជាមួយខ្ញុំក្នុងក្តីសង្ឃឹមថា ការជំនុំជម្រះក្តីនេះនឹងប្រព្រឹត្តទៅនៅក្នុងសភាពថ្លៃថ្នូរនិងសន្តិភាព។ ពេលដែលចៅក្រមប្រកាសសាលក្រម យើងសង្ឃឹមថា ប្រជាជនកម្ពុជានិងអ្នកទាំងឡាយណាដែលគាំទ្រយើង នឹងឃើញថា នៅទីបញ្ចប់ យើងនឹងនាំមកនូវយុត្តិធម៌ក្នុងនាមនៃជនរងគ្រោះ។

*នាយករដ្ឋមន្ត្រី*

# សេចក្ដីផ្ដើម



ដោយឯកឧត្ដម ប៊ិន ឈិន

*ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ និងបណ្ដាប្រទេសផ្ដល់ជំនួយសម្រាប់ទ្រទ្រង់ដំណើរការ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

កម្ពុជា និងអង្គការសហប្រជាជាតិបានសហការគ្នា និងបានបង្កើតតុលាការកូនកាត់មួយដែលមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងបានចាប់ដំណើរការរបស់ខ្លួនតាំងពីឆ្នាំ២០០៦មក ដើម្បីបញ្ចប់វប្បធម៌និទណ្ឌភាព និងទប់ស្កាត់ការវិលត្រឡប់មកវិញនូវរបបប្រល័យពូជសាសន៍ នៅក្នុងប្រទេសកម្ពុជា ឬនៅកន្លែងណាមួយនៅលើពិភពលោក។

អ.វ.ត.ក គឺជាតុលាការជាតិ ដែលបានបង្កើតឡើងក្នុងប្រទេសដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនិងបានបង្កលក្ខណៈងាយស្រួលក្នុងការផ្សះផ្សាជាតិ និងបានផ្ដល់យុត្តិធម៌មិនមែនសម្រាប់តែជនរងគ្រោះជាងបីលាននាក់ដែលបានស្លាប់នោះទេ ប៉ុន្តែក៏សម្រាប់ជនរងគ្រោះដែលបានរស់រានមានជីវិត ហើយទទួលរងទុក្ខវេទនាឈឺចាប់ខ្លោចផ្សាពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលគ្រប់គ្រងអំណាចចាប់ពីថ្ងៃទី១៧ ខែ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ រហូតទល់ពេលនេះ អ.វ.ត.ក សម្រេចបានសមិទ្ធផលផ្នែកតុលាការយ៉ាងច្រើន រួមមាន៖ (ក) សំណុំរឿង ០០១ និងសំណុំរឿង ០០២/១ ត្រូវបានបញ្ចប់ជាស្ថាពរ (ខ) សាលក្រមសំណុំរឿង ០០២/០២ រំពឹងថានឹងចេញនៅត្រីមាសទីពីរឆ្នាំ២០១៨ និង (គ) ដំណើរការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ក៏ត្រូវបានបញ្ចប់រួចហើយដែរ។ ជាងនេះទៅទៀត អ.វ.ត.ក ក៏បានបន្សល់ទុកកេរដំណែលដ៏ល្អផងដែរនៅក្នុងសង្គមកម្ពុជាផងដែរ និងក៏បានចូលរួមពង្រឹងនីតិរដ្ឋនៅកម្ពុជាដោយបានបង្កើតឱ្យមាននូវគំរូនៃការជំនុំជម្រះក្ដីមួយដោយយុត្តិធម៌ និងបើកទូលាយ ដែលស្របតាមស្ដង់ដារអន្តរជាតិ ហើយក៏បាន និងកំពុងចូលរួមក្នុងការផ្សះផ្សាជាតិ ការចងចាំ និងការទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហម រួមទាំងការផ្ទេរចំណេះដឹង និងបទពិសោធពីអ.វ.ត.ក ទៅតុលាការជាតិផងដែរ។

ខ្ញុំសូមសម្ដែងនូវការកោតសរសើរដ៏ស្មោះចំពោះអតីតប្រធានក្រុមការងារនេះគឺសម្ដេចវិបុលបញ្ញា សុខអាន ចំពោះកិច្ចខិតខំប្រឹងប្រែង និងការលះបង់មិនចេះនឿយហត់របស់សម្ដេចចាប់តាំងពីដំណើរការចរចាកិច្ចព្រមព្រៀង និងការបង្កើតនៃ អ.វ.ត.ក ព្រមទាំងដំណើរការរបស់ខ្លួនដោយរលូនរហូតដល់សម្ដេចទទួលមរណៈភាព

កាលពីខែមីនា ឆ្នាំ២០១៧ កន្លងមកនេះ។ ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ សម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែយកចិត្តទុកដាក់គាំទ្រដល់រាល់ដំណើរការទាំងឡាយរបស់អ.វ.ត.ក ចាប់តាំងពីគំនិតផ្តួចផ្តើមក្នុងការបង្កើតតុលាការរហូតដល់ការបង្កើតនាពេលថ្មីៗនេះនូវមជ្ឈមណ្ឌលតម្កល់ឯកសារពាក់ព័ន្ធនឹងអ.វ.ត.កព្រមទាំងបានគាំទ្រទាំងផ្នែកថវិកា និងសម្ភារៈ ក្នុងបុព្វហេតុនៃការចងចាំប្រវត្តិសាស្ត្រ ក៏ដូចជាចូលរួមពង្រឹង និងថែរក្សាសន្តិភាព ការបង្រួបបង្រួមជាតិ ការផ្សះផ្សាជាតិ និងការអភិវឌ្ឍសង្គមកម្ពុជាឱ្យបានរឹងមាំ និងស្ថិតស្ថេរជាយូរអង្វែង សម្រាប់មនុស្សរាប់ជំនាន់ទៅមុខទៀត។

សាធារណជនកម្ពុជាជាងកន្លះលាននាក់ បានមកឃើញដំណើរការស្វែងរកយុត្តិធម៌នៅ អ.វ.ត.កដោយផ្ទាល់ ឬតាមរយៈសកម្មភាពផ្សព្វផ្សាយរៀបចំដោយផ្នែកកិច្ចការសាធារណៈ អង្គភាពគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរបស់តុលាការ។ សៀវភៅណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមរាប់សែនក្បាលមកហើយ ដែលត្រូវបានចែកចាយ ហើយការបោះពុម្ពលើក នេះនឹងបន្តមុខងារនៅក្នុងការណែនាំបំភ្លឺអំពី អ.វ.ត.ក ដល់ប្រជាពលរដ្ឋនៅគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា និងពិភពលោកទាំងមូល ដោយឆ្លើយតបទៅនឹងសំណួរមួយចំនួនដែលតែងតែចោទសួរឡើងទាក់ទងនឹងដំណើរការជំនុំជម្រះក្តីនៃ អ.វ.ត.ក៕

*ឧបនាយករដ្ឋមន្ត្រីប្រចាំការ*

# សារលិខិត



Photo: UN/Mark Garten

*លោកអង់តូនីញ៉ូ ហ្គុតតីរ៉េស*
*អគ្គលេខាធិការ*
*អង្គការសហប្រជាជាតិ*
*ខែកញ្ញា ឆ្នាំ២០១៧*

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការត្រូវបានបង្កើតឡើង ដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាចំពោះឧក្រិដ្ឋកម្មគួរឲ្យរន្ធត់ដែលបានប្រព្រឹត្តដោយរបបខ្មែរក្រហមក្នុងទសវត្សរ៍ឆ្នាំ ១៩៧០។ ចាប់តាំងពីពេលដំណើរការរបស់ខ្លួននៅខែ មករា ឆ្នាំ ២០០៦ មក អ.វ.ត.ក សម្រេចបានវឌ្ឍនភាពយ៉ាងធំធេងក្នុងការបំពេញអាណត្តិការងាររបស់ខ្លួន។

នៅខែកុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់ការដាក់ទោសទៅលើប្រធានមន្ទីរឃុំឃាំង ស-២១ ដែលមានកេរ្តិ៍ឈ្មោះអសោចចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាត ិនិងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ដោយផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ នៅខែវិច្ឆិកា ឆ្នាំ ២០១៦ អង្គជំនុំជម្រះតុលាការកំពូលនេះបានតម្កល់ការដាក់ទោសទៅលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមពីររូប ចំពោះបទចោទស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការជំនុំជម្រះជាប្រវត្តិសាស្រ្តទាំងនេះបង្ហាញថា ការធ្វើការរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិ អាចសម្រេចបានយ៉ាងជោគជ័យក្នុងការបញ្ចប់អំពើ និទណ្ឌភាព និងធានាឲ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអន្តរជាតិ។ អ.វ.ត.ក បន្តការងារជំនុំជម្រះនាពេលបច្ចុប្បន្នយ៉ាងពេញលេញចំពោះបទចោទបន្ថែមទៀតមកលើមេដឹកនាំជាន់ខ្ពស់ទាំងពីររូបនេះ និងកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងពីរបន្ថែមទៀត។

ក្នុងអំឡុងពេលដំណើរការរយៈពេលប៉ុន្មានឆ្នាំមកនេះ អ.វ.ត.ក បានចូលរួមចំណែកពង្រឹងនីតិរដ្ឋ និងបង្កើនសមត្ថភាពក្នុងវិស័យតុលាការនៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ។ ការខិតខំប្រឹងប្រែងរបស់សាលាក្តីនេះក្នុងការផ្សព្វផ្សាយព័ត៌មានដែលបានទៅដល់ប្រជាជនជាងកន្លះលាននាក់ មានសារៈសំខាន់ណាស់ក្នុងការធានាថា ជនរងគ្រោះដោយសារអំពើឃោរឃៅមិនត្រូវបានគេបំភ្លេចចោល ខណៈពេលជាមួយគ្នានោះ ជួយដល់ប្រជាជនកម្ពុជាឲ្យធ្វើដំណើរទៅមុខទៀត។

អ.វ.ត.ក បានផ្ញើសារដ៏មានឥទ្ធិពលមួយទៅកាន់ពិភពលោកថា យើងអាចប្រយុទ្ធអំពើនិទណ្ឌភាព និងធានាឲ្យមានការទទួលខុសត្រូវ។ សាលាក្តីនេះក៏គួរតែបន្សល់ទុកនូវកេរតំណែលក្នុងវិស័យតុលាការយូរអង្វែងផងដែរ តាមរយៈការបង្កើតជាកំណត់ត្រាប្រវត្តិសាស្រ្តនៃឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនិងអនុញ្ញាតឲ្យអ្នករស់រានពីរបបនេះក្រុមគ្រួសាររបស់ពួកគេ និងសង្គមកម្ពុជា ស្វែងរកការពិត និងស្វែងរកយុត្តិធម៌។

## សំណួរទី ១ ហេតុអ្វីបានជាប្រើរយៈពេលយូរម្ល៉េះ ទើបចាប់ផ្តើមជំនុំជម្រះក្តីអ្នកដែលត្រូវបានចោទប្រកាន់ថាបានទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

ប្រវត្តិសាស្រ្តបានបង្ហាញឱ្យឃើញថា ពេលប្រទេសនៅមានសង្គ្រាមការជំនុំជម្រះក្តីជួបប្រទះការលំបាកខ្លាំង។ កម្ពុជាស្នើទៅអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៧ សុំឱ្យជួយបង្កើតតុលាការមួយ។ ចាប់តាំងពីការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជានៅឆ្នាំ ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានធ្វើការរួមគ្នាដើម្បីបង្កើតនូវទម្រង់ថ្មីមួយនៃតុលាការជំនុំជម្រះក្តីចម្រុះជាតិនិងអន្តរជាតិ។ ភាគីទាំងពីរត្រូវចំណាយពេលវេលាយូរដើម្បីពិភាក្សាលម្អិតក្នុងការបង្កើតតុលាការប្រភេទថ្មីនេះ។ តុលាការនេះត្រូវបានបង្កើតឡើងក្រោមច្បាប់ដែលអនុម័តដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ២០០១ និងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិដែលចុះហត្ថលេខានៅឆ្នាំ ២០០៣ ដែលកំណត់ពីរង្វង់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ។


រូបថត: មជ្ឈមណ្ឌលឯកសារកម្ពុជា

*កងទ័ពខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥*

## សំណួរទី ២ ហេតុអ្វីបានជាយើងទើបតែជំនុំជម្រះក្តីនៅពេលនេះ? តើការជំនុំជម្រះក្តីអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនឹងផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជនកម្ពុជា?

អស់រយៈពេលជាង ២៥ ឆ្នាំកន្លងមកហើយ ដែលប្រជាជនកម្ពុជាបានរង់ចាំយុត្តិធម៌។ ជាមួយការបង្កើត អ.វ.ត.ក អតីតមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ (ឈ្មោះរបស់រដ្ឋដែលបង្កើតឡើងដោយខ្មែរក្រហម) និងអ្នកទទួលខុសត្រូវខ្ពស់ក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត ត្រូវបាននាំយកមកឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលពួកគេប្រព្រឹត្ត។


រូបថត: អ.វ.ត.ក

*ប្រជាពលរដ្ឋជាជនរងគ្រោះអានសៀវភៅណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីខ្មែរក្រហមនៅបរិវេណតុលាការ*

សំណួរទី ៣

## តើនរណាខ្លះអាចនឹងត្រូវនាំយកមកជំនុំជម្រះក្តី?

ក្នុងស្មារតីចង់បានយុត្តិធម៌ការពិតនិងការផ្សះផ្សាជាតិ យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះមានកម្រិតចំពោះតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់ក្នុងក្រិដ្ឋកម្មធ្ងន់ធ្ងរប្រព្រឹត្តឡើងចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩។ កងទ័ពរបស់ខ្មែរក្រហមរាប់ម៉ឺននាក់ បានចុះចូលជាមួយរាជរដ្ឋាភិបាល។ ពួកគាត់គ្មានអ្វីដែលត្រូវភ័យខ្លាចអំពីតុលាការនេះទេ។គោលនយោបាយផ្សះផ្សាជាតិស្ថិតនៅជាធរមាននៅឡើយ។ សូមចងចាំថា មានតែជនដែលប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរតែប៉ុណ្ណោះដែលនឹងត្រូវជំនុំជម្រះនៅក្រោមច្បាប់ដែលមានចែងដោយអង្គជំនុំជម្រះពិសេសនេះ។

អង្គជំនុំជម្រះវិសាមញ្ញនេះមានតួនាទីកំណត់ថាតើអតីតខ្មែរក្រហមរូបណាជាមេដឹកនាំជាន់ខ្ពស់ហើយនរណាដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងឧក្រិដ្ឋកម្មនាពេលនោះ។ តុលាការនឹងស្វែងរកតែមុខសញ្ញាទាំងនោះ មិនមែនស្វែងរកគ្រប់អតីតសមាជិកខ្មែរក្រហម នៅគ្រប់ភូមិស្រុកទូទាំងប្រទេសកម្ពុជានោះទេ។

-សមាជិកខ្មែរក្រហមដែលមានបណ្តាស័ក្តិទាបឬមធ្យមដែលមិនមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងនោះនឹងមិនត្រូវនាំយកមកជំនុំជម្រះទេ។ ពួកគាត់ភាគច្រើន ឥឡូវនេះ បានចូលរួមនៅក្នុងសង្គមជាតិឡើងវិញហើយ។ យើងសង្ឃឹមថា អ្នកទាំងនោះនឹងរស់នៅដោយសុខសាន្ត និងជួយសហការអភិវឌ្ឍប្រទេសជាតិ។



## បដិរូបជាផ្លូវការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បដិរូបតំណាងឱ្យអង្គជំនុំជម្រះជាការពិពណ៌នារួមមួយនៃការគ្រប់គ្រងនៃតុលាការកម្ពុជាក្នុងសម័យអង្គរ និងអមដោយកួរផ្លែអូលីវ ជាសញ្ញារបស់អង្គការសហប្រជាជាតិដែលតំណាងឱ្យសន្តិភាព។ ពណ៌ជាផ្លូវការគឺពណ៌ខៀវចាស់។

រូបអង្គុយលើបល្ល័ង្ក ហើយកាន់ដាវមួយតំណាងឱ្យអំណាចតុលាការ។ វាគឺជារូបតាំងលើជញ្ជាំងកណ្តាលគេ នៅអតីតសាលាឧទ្ធរណ៍ក្នុងក្រសួងយុត្តិធម៌នៅទីក្រុងភ្នំពេញ។ រូបនោះអមដោយអ្នកជំនួយការពីរនាក់ដែលកំពុងអានច្បាប់ដែលចារដោយដៃលើស្លឹករឹត។

-កូន ឬសមាជិកគ្រួសារផ្សេងៗទៀត ឬអ្នកធ្លាប់រាប់អានមេដឹកនាំខ្មែរក្រហម នឹងមិនទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជំនួសឪពុកម្តាយ ឬសហគមន៍របស់ខ្លួនទេ។ គ្មាននរណាម្នាក់ត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះទង្វើរបស់បុគ្គលផ្សេងទៀតដោយគ្រាន់តែពួកគេ មានជាប់សាច់ញាតិគ្នានោះឡើយ។

-អតីតមេដឹកនាំខ្មែរក្រហមដែលបានស្លាប់បាត់បង់ជីវិតទៅហើយនឹងមិនត្រូវបានជំនុំជម្រះឡើយ។ តុលាការជំនុំជម្រះក្តីតែអ្នកដែលនៅរស់ប៉ុណ្ណោះ។


Tom Fawthrop

*កងទ័ពខ្មែរក្រហមបន្ទាប់ពីទម្លាក់អាវុធនិងធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា*

## សំណួរទី ៤ តើជនជាប់ចោទនឹងទទួលទោសអ្វីខ្លះ ប្រសិនបើតុលាការរកឃើញថាគាត់មានទោស?

ប្រសិនបើរកឃើញថាមានពិរុទ្ធភាព ជនជាប់ចោទនឹងបត្រូវប្រឈមមុខនឹងការផ្តន្ទាទោសអតិបរមាគឺការដាក់ពន្ធនាគារអស់មួយជីវិតហើយការដាក់ទោសអប្បរមាគឺការដាក់ពន្ធនាគាររយៈពេល ៥ ឆ្នាំ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឱ្យមានទោសប្រហារជីវិតទេ។ បន្ថែមពីលើនេះ តុលាការអាចបញ្ជាឱ្យធ្វើការរឹបអូសទ្រព្យសម្បត្តិ ឬថវិកាដែលចុងចោទទទួលបានមិនស្របច្បាប់ឬដោយការប្រព្រឹត្តិបទឧក្រិដ្ឋណាមួយ។ ទ្រព្យសម្បត្តិដែលបានរឹបអូសនឹងត្រូវប្រគល់ជូនរដ្ឋ។ កាំង ហ្កេកអ៊ាវ ហៅឌុច នួន ជា និង ខៀវ សំផន ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

## សំណួរទី ៥ តើមានការលើកលែងទោសឬការអនុគ្រោះទោសដែរឬទេ?

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសរួចជាស្រេចហើយនៅក្នុងច្បាប់និងកិច្ចព្រមព្រៀងថា ខ្លួននឹងមិនស្នើសុំឱ្យមានការលើកលែងទោស ឬការអនុគ្រោះទោសសម្រាប់ជនណាម្នាក់ដែលត្រូវបានស៊ើបអង្កេត ឬត្រូវបានអង្គជំនុំជម្រះវិសាមញ្ញរកឃើញថាមានទោសទេ។

## សំណួរទី ៦ តើមានមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណាម្នាក់ធ្លាប់ត្រូវបានជំនុំជម្រះពីមុនមកដែរឬទេ ?

នៅឆ្នាំ១៩៧៩ មានការជំនុំជម្រះក្តីទៅលើអំពើប្រល័យពូជសាសន៍នៅទីក្រុងភ្នំពេញដែលគេស្គាល់ថាជាតុលាការប្រជាជនបដិវត្តន៍។ តុលាការនេះបានកាត់ទោស ប៉ុល ពត និង អៀង សារី ហើយបានរកឃើញថា អ្នកទាំងពីរមានពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ក៏ប៉ុន្តែ ជនជាប់ចោទមិនមានវត្តមាននៅចំពោះមុខតុលាការទេហើយក៏មិនបានទទួលទោសដែលតុលាការប្រជាជនបដិវត្តន៍បានសម្រេចនោះដែរ។ នៅឆ្នាំ១៩៩៧ ក្រុមខ្មែរក្រហមខ្លួនឯងផ្ទាល់បានជំនុំជម្រះ ប៉ុល ពត ពីបទឧក្រិដ្ឋ ដែលគាត់បានប្រព្រឹត្តនៅក្នុងរង្វង់អង្គការរបស់គាត់ ក្រោយឆ្នាំ១៩៧៩។ ប៉ុល ពត ស្លាប់នៅឆ្នាំ ១៩៩៨។ ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញមិនអាចជំនុំជម្រះទោសប៉ុល ពត បានទេ។



សារព័ត៌មានខ្មែរ (SPK)

*សវនាការដំបូងរបស់តុលាការប្រជាជនបដិវត្តន៍ ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៩*



## សំណួរទី ៧ តើបណ្តាប្រទេសដែលធ្លាប់បានគាំទ្រ ឬក៏ធ្លាប់ជាប់ពាក់ព័ន្ធជាមួយរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏បណ្តាប្រទេសដែលប្រហែលជាបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមនៅកម្ពុជា មុនឆ្នាំ១៩៧៥ នឹងត្រូវប្រឈមមុខនឹងការជំនុំជម្រះដែរឬទេ ?

ទេ! អង្គជំនុំជម្រះវិសាមញ្ញអាចជំនុំជម្រះតែបុគ្គលណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ។ តុលាការនេះមិនអាចជំនុំជម្រះប្រទេស ឬអង្គការណាមួយឡើយ។

## សំណួរទី ៨ តើនឹងមានការជំនុំជម្រះក្តីចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តដោយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមឬអ្នកដទៃទៀតក្រោយឆ្នាំ១៩៧៩ ដែរឬទេ ?

ទេ! តុលាការនេះជំនុំជម្រះក្តីតែឧក្រិដ្ឋកម្មណាដែលបានប្រព្រឹត្តនៅកម្ពុជាចន្លោះពីថ្ងៃទី១៧ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី តុលាការថ្នាក់ជាតិមានអំណាចនឹងជំនុំជម្រះក្តីលើឧក្រិដ្ឋកម្មផ្សេងទៀតដែលបានកើតឡើងក្រោយរបបខ្មែរក្រហម។ ឧទាហរណ៍ ការជំនុំជម្រះក្តីនាយទាហានខ្មែរក្រហមដែលទទួលខុសត្រូវពីបទពួនស្ទាក់វាយប្រហារខ្សែរថភ្លើងពីភ្នំពេញទៅខេត្តកំពតកាលពីឆ្នាំ១៩៩៤ ដែលបានសម្លាប់អ្នកដំណើរជាជនជាតិខ្មែរ ១១នាក់ និងសម្លាប់ចំណាប់ខ្មាំងបស្ចិមប្រទេស ៣នាក់ បានប្រព្រឹត្តទៅនៅក្នុងតុលាការក្នុងស្រុកដោយគ្មានជំនួយពីអង្គការសហប្រជាជាតិទេ។

## សំណួរទី ៩ តើមានសំណុំរឿងប៉ុន្មានកំពុងដំណើរការនៅ អ.វ.ត.ក ?

សំណុំរឿងនៅចំពោះមុខ អ.វ.ត.ក មានចំនួន ៤ ដែលគេស្គាល់ថាជាសំណុំរឿង ០០១, ០០២, ០០៣, ០០៤។ សំណុំរឿងខ្លះត្រូវបានបំបែកកិច្ចដំណើរការនីតិវិធីជាសំណុំរឿងជាច្រើនទៀត។ សំណុំរឿង ០០១ ត្រូវបានបញ្ចប់ជាស្ថាពរនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២។ សំណុំរឿង ០០២ ត្រូវ បំបែកជាសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២។ សំណុំរឿង ០០២/០១ ត្រូវបានបញ្ចប់ នៅខែវិច្ឆិកា ឆ្នាំ ២០១៦។ ចំណែកសំណុំរឿង ០០២/០២ កំពុងដំណើរការ។ សំណុំរឿង ០០៣ និង ០០៤ កំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេត។ សំណុំរឿង ០០៤ ត្រូវបានបំបែកជាសំណុំរឿង ០០៤/០១, ០០៤/០២ និងសំណុំរឿង ០០៤។

**កាំង ហ្កេកអ៊ាវ ហៅ ឌុច**

អតីតប្រធានមន្ទីរសន្តិសុខ ស-២១ នៅទីក្រុងភ្នំពេញ បច្ចុប្បន្នសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។


រូបថត: អ.វ.ត.ក

### សំណុំរឿង ០០១

ការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០១ ប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ឌុចត្រូវបានជំនុំជម្រះនៅឆ្នាំ២០០៩ ហើយនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឌុច ត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។ អំឡុងពេលនៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ការផ្តល់សក្ខីកម្មរបស់មនុស្សចំនួន ៥៥ រូបដែលរួមមានសាក្សីអង្គហេតុចំនួន ១៧ រូប អ្នកជំនាញចំនួន ៩ រូប សាក្សីអត្តចរិត ចំនួន ៧ រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២ រូប។ អង្គជំនុំជម្រះសាលាដំបូងបានផ្តន្ទាទោស ឌុច ដាក់ពន្ធនាគាររយៈពេល ៣៥ ឆ្នាំ និងកាត់បន្ថយ ៥ ឆ្នាំ ជាការសងជំងឺចិត្តចំពោះការដែលគាត់ត្រូវជាប់ឃុំឃាំងមិនប្រក្រតីនៅមន្ទីរឃុំឃាំងរបស់តុលាការយោធា។ ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៦ នាក់ ក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩០នាក់។

ជនជាប់ចោទ សហព្រះរាជអាជ្ញា និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីកាស្ថាពរដោយសម្រេចផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារអស់មួយជីវិត ដោយពុំមានការបន្ធូរបន្ថយទោសចំពោះការជាប់ឃុំឃាំងមិនប្រក្រតីឡើយ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ១០ នាក់ទៀត។ ដូច្នេះជាសរុបដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៧៦ នាក់ ត្រូវបានទទួលស្គាល់ និងបានទទួលសំណងផ្លូវចិត្ត និងសំណងសមូហភាព។ សាធារណជនចំនួន៣៦ ៤៩៣ បានចូលរួមស្តាប់ដំណើរការជំនុំជម្រះក្តី និងសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ប្រឆាំងនឹងឌុច។


រូបថត: អ.វ.ត.ក.

*ឌុច ទទួលសាលដីកាស្ថាពរសម្រាប់រូបគាត់ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២*

ឌុចបានចាប់ផ្តើមទទួលទោសរបស់គាត់នៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក. នៅឆ្នាំ ២០១២ ហើយបន្ទាប់មកត្រូវបានផ្ទេរទៅពន្ធនាគារខេត្តកណ្តាល នៅខែមិថុនា ឆ្នាំ២០១៣ ដើម្បីទទួលទោសដែលមាននៅសល់។

**នួន ជា**

អតីតប្រធានរដ្ឋសភា នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា


រូបថត: អ.វ.ត.ក.

**ខៀវ សំផន**

អតីតប្រមុខរដ្ឋ នៃរបបកម្ពុជាប្រជាធិបតេយ្យ


រូបថត: អ.វ.ត.ក.

## សំណុំរឿង ០០២

ដំបូងឡើយ សំណុំរឿង ០០២ មានជាប់ចោទចំនួន ៤ រូប ប៉ុន្តែបច្ចុប្បន្ននេះ អតីតមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យចំនួន ២ រូបប៉ុណ្ណោះដែលកំពុងត្រូវបានជំនុំជម្រះក្តី។ ជនជាប់ចោទទាំង ២ រូបមាន៖ នួន ជា និងខៀវ សំផន។ ជនជាប់ចោទទាំង ២ រូបត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម និងវៀតណាម។

## អៀង សារី

អតីតឧបនាយករដ្ឋមន្ត្រី
ទទួលបន្ទុកការបរទេស
នៃរបបកម្ពុជាប្រជាធិបតេយ្យ



រូបថត: អ.វ.ត.ក/ម៉ាក ពីទ័រ

## អៀង ធីរិទ្ធ

អតីតរដ្ឋមន្ត្រីសង្គមកិច្ច



រូបថត: អ.វ.ត.ក

ជនជាប់ចោទពីររូបផ្សេងទៀតលែងមានជាប់ពាក់ព័ន្ធនឹងការជំនុំជម្រះក្តីនេះហើយ។ អៀង សារី និង អៀង ធីរិទ្ធ ត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មប្រល័យពូជសាសនៅក្នុងសំណុំរឿង ០០២។ ប៉ុន្តែ អៀង សារី បានស្លាប់នៅខែមីនា ឆ្នាំ ២០១៣ ហើយបទចោទប្រកាន់នានាប្រឆាំងនឹង អៀង សារី ត្រូវបានលុបចោលបន្ទាប់ពីមរណភាពរបស់គាត់។ ដោយឡែក បទចោទប្រកាន់ប្រឆាំងនឹង អៀង ធីរិទ្ធ ស្ថិតនៅដដែលតាំងពីខែវិច្ឆិកា ឆ្នាំ២០១១ បើទោះជា

គាត់ត្រូវបានរកឃើញថាមានជំងឺបាត់ការចងចាំមិនអាចចូលរួមសវនាការបាន។ លោក ស្រី អៀង ធីរិទ្ធ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ននៅខែកញ្ញា ឆ្នាំ ២០១២ ហើយ គាត់បានស្លាប់នៅខែសីហា ឆ្នាំ ២០១៥។

អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការបឋមលើសំណុំរឿង ០០២ នៅខែមិថុនា ឆ្នាំ ២០១១។ ចាប់តាំងពីពេលនោះមក សំណុំរឿង ០០២ ត្រូវបានបំបែកកិច្ចដំណើរការនីតិវិធីជា សំណុំរឿង ០០២/០១ និង ០០២/០២ ហើយសំណុំរឿងនីមួយមានផ្នែកនៃបទចោទផ្សេងៗគ្នា។

### សំណុំរឿង ០០២/០១

ការជំនុំជម្រះទី១ ក្នុងសំណុំរឿង ០០២ គឺសំណុំរឿង ០០២/០១ បានចាប់ផ្តើមដំបូងដោយផ្តោតលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលទាក់ទងនឹងការជម្លៀសបរជាជនដោយបង្ខំពីទីក្រុងភ្នំពេញ(ដំណាក់កាលទី១) និងបន្តបន្ទាប់ទៀតពីតំបន់ផ្សេងៗទៀត ដំណាក់កាលទី២ ហើយនឹងបទចោទទាក់ទងនឹងការសមលាប់អតីតមន្ត្រីនៃរបបសាធារណរដ្ឋ លន់ នល់ នៅទួលពោធិ៍ជ្រៃ ខេត្តពោធិ៍សាត់។ សវនាការសួរដេញដោលលើភ័ស្តុតាងបានចាប់ផ្តើមឡើងនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ហើយបានបិទបញ្ចប់នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៣។




រូបថត: អ.វ.ត.ក

*អង្គជំនុំជម្រះតុលាការកំពូលប្រកាសសាលដីកាលើសំណុំរឿង ០០២/០១ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦។*

ក្នុងអំឡុងពេលនៃដំណើរការសវនាការនេះ បុគ្គលចំនួន ៩២ នាក់ត្រូវបានកោះហៅមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងនោះ សាក្សីអង្គហេតុចំនួន ៥៣ រូប សាក្សីអត្តចរិតចំនួន៥ រូប និងដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣១ រូប និងសាក្សីជាអ្នកជំនាញចំនួន ៣រូបនិងមានសាធារណជនចំនួន ១០៣ ៧២៤ នាក់បានចូលរួមតាមដានដំណើរការសវនាការដោយផ្ទាល់នៅសាលាសវនាការរបស់ អ.វ.ត.ក.។

នៅថ្ងៃទី៧ ខែសីហា ឆ្នាំ ២០១៤ ជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថា មានពិរុទ្ធភាព ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះដ៏ច្រើនបានទទួលរងនូវការឈឺចាប់ដែលមិនអាចវាស់វែងបាន ហេតុដូច្នេះ អង្គជំនុំជម្រះគាំទ្រលើការអនុវត្តគម្រោងសំណងជំងឺចិត្ត ចំនួន ១១ ដែលបានរៀបចំឡើងសមស្របដើម្បីទទួលស្គាល់នូវការឈឺចាប់នេះ។ ជនជាប់ចោទទាំងពីរ និងសហព្រះរាជអាជ្ញាបានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ ។



រូបថត: អ.វ.ត.ក

ជនជាប់ចោទ នួន ជា និងខៀវ សំផន ស្ដាប់ការប្រកាសសាលក្រនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦។

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ អង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីកាដោយ បានទម្លាក់ចោលបទចោទមួយចំនួន និងរក្សាទុកអង្គហេតុដែលនៅសល់ ហើយបានសម្រេច តម្កល់ការផ្ដន្ទាសទោសដាក់ពន្ធនាគារអស់មួយជីវិតប្រឆាំងនឹង នួន ជា និង ខៀវ សំផន ចំពោះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

## សំណុំរឿង ០០២/០២

ការជំនុំជម្រះទី ២ នៃសំណុំរឿង០០២ គឺសំណុំរឿង០០២/០២ ផ្ដោតលើបទចោទប្រកាន់លើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើជនជាតិចាមនិងជនជាតិវៀតណាម ការរំលោភបំពារបំពារយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ការរៀបការដោយបង្ខំ ការរំលោភសេពសន្ថវៈការបោសសម្អាតផ្ទៃក្នុង ការធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិកជន ក៏ដូចជា បទចោទលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខចំនួន ៤ ការដ្ឋានការងារចំនួន ៣ និងនៅសហករណ៍ត្រាំកក់។

សវនាការជំនុំជម្រះក្ដីប បានចាប់ផ្ដើមឡើងនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៤ ហើយសវនាការលើអង្គសេចក្ដីបានចាប់ផ្ដើមឡើង នៅថ្ងៃទី៨ ខែមករា ឆ្នាំ ២០១៥ ហើយបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។

នៅក្នុងអំឡុងពេលនៃដំណើរការសវនាការ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សាក្សីចំនួន ១១៤ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣ នាក់ និងអ្នកជំនាញ ចំនួន ៨ នាក់។

សវនាការលើសំណុំរឿងនេះ បានបញ្ចប់ជាមួយសវនាការធ្វើសេចក្តីសន្និដ្ឋានបិទ បញ្ចប់ការសួរដេញដោលលើភស្តុតាងចំនួន ៩ ថ្ងៃ ពីថ្ងៃទី ១៣ ដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០១៧។ ដំណើរការសវនាការនេះទទួលបាននូវការចូលរួមពីសាធារណជនចំនួន ៨២ ៧៨០នាក់ ដែលបានចូលស្តាប់សវនការរយៈពេល ២៨៣ ថ្ងៃ។ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងប្រកាសសេចក្តីសម្រេច និងសាលក្រមរបស់ខ្លួននៅអំឡុងត្រីមាសទី២ ឆ្នាំ ២០១៨ ខាងមុខ។



រូបថត: អ.វ.ត.ក

*អង្គជំនុំជម្រះសាលាដំបូងបើកសវនាការលើសំណុំរឿង ០០២/០២ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៥។*

## សំណុំរឿង ០០៣ និង ០០៤

សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើសំណើនៅឆ្នាំ២០០៩ សុំឱ្យសហចៅក្រមស៊ើបអង្កេត បើកការស៊ើបអង្កេតលើបទឧក្រិដ្ឋផ្សេងៗទៀត ដែលត្រូវបានជឿថាជាប់ទាក់ទងនឹងជនសង្ស័យចំនួន ៥ នាក់បន្ថែមទៀត។ ដំណើរការនេះត្រូវបានដាក់ឈ្មោះថា សំណុំរឿង ០០៣ និង ០០៤។ សំណុំរឿង ០០៤ ត្រូវបានបំបែកចេញជាបីសំណុំរឿងគឺសំណុំរឿង ០០៤/០១, ០០៤/០២ និងសំណុំរឿង ០០៤។ ការចោទប្រកាន់សំខាន់ៗនៅក្នុងសំណុំរឿង ០០៣ និង០០៤ ផ្តោតលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពារ បំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និងការរំលោភបំពានលើក្រមព្រហ្ម ទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ទាក់ទងនឹងអំពើមនុស្សឃាត។

## សំណុំរឿង ០០៣

បុគ្គលចំនួនពីររូបត្រូវបានកំណត់ថាជាជនសង្ស័យនៅក្នុងសំណុំរឿង ០០៣។ ដំណើរការ ស៊ើបអង្កេតតាមផ្លូវតុលាការប្រឆាំងនឹង ស៊ូ ម៉េត ត្រូវបានបញ្ចប់នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ ២០១៥ ក្រោយពីលោកបានស្លាប់។ ជនសង្ស័យទី២ គឺ មាស មុត ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខកាលពីខែមីនា ឆ្នាំ ២០១៥។ មាស មុត បានបង្ហាញខ្លួនដោយស្ម័គ្រចិត្តនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅខែធ្នូឆ្នាំ២០១៥ដែលនៅពេលនោះលោកត្រូវបានប្រាប់អំពីបទចោទប្រកាន់បន្ថែមប្រឆាំងនឹងរូបគាត់។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបិទបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត។

## មាស មុត



ត្រូវបានដាក់ឱ្យស្ថិតក្រោម
ការត្រួតពិនិត្យដោយកំបាំងមុខ
នៅថ្ងៃទី៣ ខែមីនា ឆ្នាំ ២០១៥

## អ៊ឹម ចែម



ត្រូវបានដាក់ឱ្យស្ថិតក្រោម
ការត្រួតពិនិត្យដោយកំបាំងមុខ
នៅថ្ងៃទី៣ ខែមីនា ឆ្នាំ ២០១៥

រូបថត: អ.វ.ត.ក

### សំណុំរឿង ០០៤/០១

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខនៅក្នុងសំណុំរឿង ០០៤។ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ ២០១៦ សំណុំរឿងនេះត្រូវបានបំបែកជាសំណុំរឿង០០៤/០១។នៅថ្ងៃទី២២ខែកុម្ភៈ ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម ដោយរកឃើញថា គាត់មិនស្ថិតនៅក្នុងដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក មានន័យថា លោកស្រី អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវខ្ពស់ក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ បំផុតនៃរបបខ្មែរក្រហមឡើយ។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។ បណ្តឹងសាទុក្ខនេះនឹងត្រូវដោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះ។

### សំណុំរឿង ០០៤/០២

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ អោ អាន ឱ្យស្ថិតក្រោមការត្រួតពិនិត្យនៅ ក្នុងសំណុំរឿង ០០៤ កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៥ ហើយនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០១៦ គាត់ត្រូវបានបន្ថែមការចោទប្រកាន់មួយចំនួនទៀត។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៦ សហចៅ ក្រមស៊ើបអង្កេតបានបិទបញ្ចប់ការស៊ើបអង្កេតប្រឆាំងនឹងអោអានហើយសំណុំរឿងត្រូវបានបំបែកជាសំណុំរឿង ០០៤/០២។

### សំណុំរឿង ០០៤

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ យឹម ទិត្យ ឱ្យស្ថិត ក្រោមការត្រួតពិនិត្យក្នុងសំណុំរឿង ០០៤។ សំណុំរឿង ០០៤នៅតែជាសំណុំរឿងប្រឆាំងនឹង យឹម ទិត្យ បន្ទាប់ពីមានការបំបែកសំណុំរឿង និងបង្កើតជាសំណុំរឿង ០០៤/០១ និងសំណុំរឿង ០០៤/០២។ នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានបិទបញ្ចប់ការស៊ើប អង្កេតប្រឆាំងនឹង យឹម ទិត្យ។

## អោ អាន



ត្រូវបានដាក់ឱ្យស្ថិតក្រោម
ការត្រួតពិនិត្យ
ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៥

## យឹម ទិត្យ



ត្រូវបានដាក់ឱ្យស្ថិតក្រោម
ការត្រួតពិនិត្យ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ ២០១៥

## សំណួរទី ១០ តើការជំនុំជម្រះក្តីនឹងប្រើរយៈពេលប៉ុន្មានឆ្នាំ ?

រយៈពេលនៃការជំនុំជម្រះក្តីអាស្រ័យថាតើអ្នកស៊ើបអង្កេតត្រូវការរយៈពេលប៉ុន្មានដើម្បីប្រមែប្រមូលភ័ស្តុតាង តើមានមនុស្សប៉ុន្មាននាក់នឹងត្រូវយកមកជំនុំជម្រះ តើមានសាក្សីប៉ុន្មាននាក់នឹងត្រូវកោះអញ្ជើញមកបំភ្លឺនៅតុលាការ ហើយថាតើនឹងមានការប្តឹងឧទ្ធរណ៍ប៉ុន្មានករណី។ នៅពេលដែលការជំនុំជម្រះចប់សព្វគ្រប់ អ.វ.ត.កនឹងរលាយខ្លួនជាស្វ័យប្រវត្តិ។

មន្ត្រី និងបុគ្គលិកទាំងអស់របស់តុលាការដឹងអំពីភាពបន្ទាន់នៃការជំនុំជម្រះក្តីនិងកំពុងប្រឹងប្រែងធ្វើការដើម្បីបញ្ចប់ការងាររបស់ អ.វ.ត.ក ឱ្យបានលឿនតាមតែអាចធ្វើបាន និងស្របតាមបទដ្ឋានអន្តរជាតិ។




## សំណួរទី ១១ តើការជំនុំជម្រះក្តីនេះប្រព្រឹត្តទៅនៅទីណា ?

ការជំនុំជម្រះក្តីប្រព្រឹត្តទៅនៅសាលសវនាការនៃ អ.វ.ត.ក ដែលស្ថិតនៅជាយរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៤ ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ។

## សំណួរទី ១២ តើអង្គជំនុំជម្រះវិសាមញ្ញធ្វើការរបៀបដូចម្តេច ?

សំណុំរឿង ត្រូវបានចែកចែកជាដំណាក់កាលនៃការស៊ើបអង្កេត និងការជំនុំជម្រះ។ ការស៊ើប អង្កេតចាប់ផ្តើមឡើងនៅពេលសហព្រះរាជអាជ្ញា (ជនជាតិកម្ពុជាមួយរូបនិងបរទេសមួយរូប) ដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបឋមដោយឈរលើមូលដ្ឋាននៃការស៊ើបអង្កេតបឋមរបស់ខ្លួនទៅកាន់សហចៅក្រមស៊ើបអង្កេត (ជនជាតិកម្ពុជាមួយរូបនិងបរទេសមួយរូប)។ សហចៅក្រមស៊ើបអង្កេត ដឹកនាំការស៊ើបអង្កេតដោយឥតលម្អៀងរបស់ខ្លួនទៅលើអង្គហេតុដែលបាន លើកឡើងក្នុងដីការបញ្ជូនរឿងឱ្យស៊ើបសួរ និងដីការបញ្ជូនរឿង ឱ្យស៊ើបសួរបន្ថែមដើម្បីស្វែងរកការពិត។ ប្រសិនបើចៅក្រមស៊ើបអង្កេតរកឃើញថាមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ទៅលើជនត្រូវចោទក្នុងអំពើឧក្រិដ្ឋកម្មដែលស្ថិតក្នុងដែនយុត្តាធិការរបស់តុលាការ នោះពួកគាត់នឹងចេញដីកាដំណោះស្រាយចោទប្រកាន់ និងបញ្ជូនសំណុំរឿងឱ្យជំនុំជម្រះ។ ប្រសិនបើគ្មានភស្តុតាងគ្រប់គ្រាន់ទេ ពួកគាត់នឹងចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់។ អង្គបុរេជំនុំជម្រះ (សមាសភាពចូលរួមពីចៅក្រមកម្ពុជាចំនួន ៣ រូប និងចៅក្រមបរទេសចំនួន ២ រូប) សម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងការសម្រេចទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេត។

ដំណាក់កាលជំនុំជម្រះក្តីចាប់ផ្តើមឡើងជាមួយការចោទប្រកាន់។ អង្គជំនុំជម្រះសាលាដំបូង (សមាសភាពចូលរួមពីចៅក្រមកម្ពុជាចំនួន ៣ រូប និងចៅក្រមបរទេសចំនួន ២ រូប) ធ្វើសវនាការស្តាប់ភស្តុតាង និងទឡ្ហីករណ៍នានា ពីសហព្រះរាជអាជ្ញា ក្រុមការពារក្តី ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបទចោទដែលមានក្នុងដីកាដំណោះស្រាយ។

បន្ទាប់ពីបានពិនិត្យលើភស្តុតាង ដែលដាក់បង្ហាញ និងទឡ្ហីករណ៍ដែលបានលើកឡើងនៅអំឡុងពេលសវនាការ អង្គជំនុំជម្រះ សាលាដំបូងចេញសាលក្រមមួយសម្រេចថា តើជនជាប់ចោទត្រូវបានគេរកឃើញថា មានពិរុទ្ធភាព ឬមិនមានពិរុទ្ធភាព។ ក្នុងករណីដែលជនជាប់ចោទ ត្រូវបានរកឃើញថាមានពិរុទ្ធភាព សាលក្រមនឹងកំណត់អំពីការផ្តន្ទាទោស និងអាចបញ្ជាឱ្យផ្តល់សំណងដល់ជនរងគ្រោះ។ អង្គជំនុំជម្រះតុលាការកំពូល (សមាសភាពចូលរួមពីចៅក្រមកម្ពុជាចំនួន ៤ រូប និងចៅក្រមបរទេសចំនួន ៣ រូប) មានតួនាទីក្នុងការសម្រេចសេចក្តីលើបណ្តឹងសាទុក្ខឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។



## សំណួរទី ១៣ តើនរណាខ្លះអាចចូលទៅស្តាប់ការជំនុំជម្រះក្តីបាន?

ការជំនុំជម្រះក្តីនេះគឺសម្រាប់ប្រជាជនកម្ពុជា។ បុគ្គលគ្រប់រូបដែលមានអាយុចាប់ពី១៨ឆ្នាំឡើងរួមទាំងជនបរទេសផង អាចចូលស្តាប់ការជំនុំជម្រះក្តីបាន។ បុគ្គលដែលមានអាយុ ១៦-១៨ ឆ្នាំ អាចចូលបានដោយមានមនុស្សចាស់មកជាមួយ។ គ្មានការបង់ប្រាក់ដើម្បីចូលស្តាប់សវនាការឡើយ ហើយមានកៅអីរាប់រយដែលត្រៀមបម្រុងទុកសម្រាប់សាធារណជនទូទៅ។ រាល់សវនាការនៅ អ.វ.ត.ក បើកចំហជូនសាធារណជនគ្រប់ពេលវេលាលើកលែងតែក្នុងស្ថានការណ៍ពិសេសដែល ចៅក្រមសម្រេចថាសវនាការត្រូវប្រព្រឹត្តទៅជាសម្ងាត់ដើម្បីការពារអត្តសញ្ញាណរបស់សាក្សី ឬរបស់ជនរងគ្រោះ។

អ.វ.ត.ក បានទទួលការគាំទ្រយ៉ាងខ្លាំងពីសាធារណជន និងមានចំនួនប្រជាពលរដ្ឋទូទៅយ៉ាងច្រើន មិនធ្លាប់មាន បានចូលរួមនៅក្នុងសកម្មភាពរបស់តុលាការនេះ។ ប្រជាពលរដ្ឋច្រើនជាង ២៤ ១០០០ នាក់រួមមានប្រជាពលរដ្ឋធម្មតារហូតដល់ថ្នាក់ដឹកនាំបរទេសបានចូលរួមស្តាប់សវនាការសាធារណៈ។ សធារណជនជាង ៥៥០០០០ នាក់បានទទួលការផ្សព្វផ្សាយអំពីសាលាក្តីខ្មែរក្រហម តាមរយៈសកម្មភាពផ្សព្វផ្សាយដ៏សកម្មរបស់តុលាការរាប់បញ្ចូលទាំងសវ នាការសាធារណៈ និងដំណើរទស្សនកិច្ចសិក្សា។ សាធារណជនភាគច្រើនគឺប្រជាជនកម្ពុជាមក ពីតាមខេត្តនានាក្នុងប្រទេសកម្ពុជា។

អ.វ.ត.កផ្តល់រថយន្តក្រុងដឹកជញ្ជូនជាក្រុមដល់ប្រជាជនកម្ពុជាដែលចង់ធ្វើទស្សនកិច្ចនៅតុលាការ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងផ្នែកកិច្ចការសាធាណៈតាមរយៈទូរស័ព្ទលេខ ០២៣ ៨៦១ ៥០០ ឬតាមរយៈសារអេឡិចត្រូនិក pas@pas.eccc.gov.kh

## សំណួរទី ១៤ ប្រសិនបើយើងមិនអាចចូលទៅស្តាប់ការជំនុំជម្រះក្តីដោយផ្ទាល់បាន តើធ្វើដូចម្តេចយើងអាចដឹងអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងតុលាការ?

ប្រជាពលរដ្ឋនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅទូទាំងសកលលោក ចង់ដឹងអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងសវនាការជំនុំជម្រះក្តី។ លោកអ្នកអាចតាមដានព្រឹត្តិការណ៍ទាំងនោះបានតាមរយៈវិទ្យុ ទូរទស្សន៍ និងបណ្តាញសារព័ត៌មាន ជាតិនិងអន្តរជាតិ។

អ.វ.ត.ក ចែកចាយព័ត៌មានអំពីការងាររបស់ខ្លួននៅទូទាំងប្រទេសកម្ពុជា រួមមាន ការចែកចាយកូនសៀវភៅណែនាំ ផ្ទាំងបិទផ្សាយព័ត៌មាន ស្លាកបិទផ្សាយព័ត៌មាន និងសម្ភារៈ ឬឯកសារផ្សព្វផ្សាយដទៃទៀត។ ក្រៅពីនេះ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានបង្កើតកម្មវិធីផ្សព្វផ្សាយ ក្នុងគោលបំណងជួយឱ្យប្រជាជនកម្ពុជាយល់ដឹងអំពីដំណើរការជំនុំជម្រះក្តីរបស់ អ.វ.ត.ក។ (សម្រាប់ព័ត៌មានបន្ថែម សូមមើលទំព័រ *ប្រភពព័ត៌មាន*)

អ.វ.ត.ក សហការជាមួយវិទ្យុបាយ័ន បង្កើតកម្មវិធីវិទ្យុប្រចាំសប្តាហ៍ផ្សាយរៀងរាល់ថ្ងៃព្រហស្បតិ៍ វេលាម៉ោង ១២:០០ ដល់ ១ រសៀល តាមរលកធាតុអាកាស FM ៩៥ មេហ្គាហឺត។ កម្មវិធីនេះផ្តល់ព័ត៌មានសង្ខេបអំពីដំណើរការសវនាការនៅក្នុងសប្តាហ៍។

## សំណួរទី ១៥ តើចៅក្រមត្រូវបានតែងតាំងឡើងយ៉ាងដូចម្តេច?

ទាំងចៅក្រម សហព្រះរាជអាជ្ញា ជាតិនិងអន្តរជាតិ ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាជ្រើសរើសចៅក្រមជាតិ ពីក្នុងចំណោមចៅក្រមដែលកំពុងបម្រើការនៅក្នុងស្ថាប័នតុលាការ។ សម្រាប់ចៅក្រមអន្តរជាតិ អគ្គលេខាធិការអង្គការសហប្រជាជាតិជ្រើសតាំងចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិមួយចំនួនបន្ទាប់មកផ្ញើបញ្ជីឈ្មោះមកជូន ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា។ នីតិវិធីដូចគ្នានឹងត្រូវអនុវត្តសម្រាប់ការចាត់តាំងចៅក្រមឬសហព្រះរាជអាជ្ញាថ្មី។

ទាំងចៅក្រមកម្ពុជានិងចៅក្រមអន្តរជាតិដែលត្រូវបានជ្រើសរើសត្រូវតែមានចរិយាសម្បត្តិថ្លៃថ្នូរទៅតាមចរិតលក្ខណៈប្រទេសរបស់គាត់ផ្ទាល់ និងត្រូវតែមានភាពស្មោះត្រង់និងឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន។ គាត់មិនត្រូវទទួលការបង្គាប់បញ្ជាពីជនណាម្នាក់ ពីរាជរដ្ឋាភិបាល ឬពីប្រភពណាផ្សេងទៀតឡើយ។ ចៅក្រមទាំងអស់បានទទួលការបណ្តុះបណ្តាលច្បាស់លាស់អំពីច្បាប់ជាតិនិងច្បាប់អន្តរជាតិ ព្រមទាំងពីនីតិវិធីទាំងឡាយដែលពាក់ព័ន្ធនឹងកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញ។


រូបថត: អ.វ.ត.ក

*កម្មវិធីផ្តល់បទឧទ្ទេសនាមដល់សិស្សវិទ្យាល័យ*

## សំណួរទី ១៦ តើអង្គចៅក្រមនឹងឈានដល់ការចេញសេចក្តីសម្រេចយ៉ាងដូចម្តេច ?

នៅក្នុងដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ចៅក្រមទាំងអស់នឹងព្យាយាមសម្រេចឱ្យបាននូវការព្រមព្រៀងគ្នាជាឯកច្ឆន្ទ ទៅលើរាល់សេចក្តីសម្រេចចិត្ត ឬសាលក្រមណាមួយដែលបានធ្វើឡើង។ ប្រសិនបើចៅក្រមមិនយល់ស្របគ្នាជាឯកច្ឆ័ន្ទនោះទេ សេចក្តីសម្រេចនឹងត្រូវធ្វើឡើងដោយសំឡេង "ភាគច្រើនលើសលប់"។ នៅសាលាដំបូងត្រូវតែមានចៅក្រម ៤ រូប ក្នុងចំណោមចៅក្រម ៥ រូប បោះឆ្នោតយល់ព្រមសម្រេចសេចក្តីឱ្យជាប់ទោស ហើយនៅតុលាការកំពូលត្រូវតែមានចៅក្រម ៥រូបក្នុងចំណោមចៅក្រម ៧រូប បោះឆ្នោតយល់ព្រមលើសេចក្តីសម្រេច ឬលើសាលដីកាស្ថាពរ។

ដូច្នេះ រាល់សេចក្តីសម្រេចចិត្តត្រូវតែមានការគាំទ្រទាំងចៅក្រមកម្ពុជា និងចៅក្រមអន្តរជាតិ។ ដោយផ្អែកតាមរូបមន្តនេះ ប្រសិនបើពុំមានសំឡេង "ភាគច្រើនលើសលប់" ទេនោះ ចុងចោទនឹងត្រូវរួចផុតពីការចោទប្រកាន់។ ការណ៍នេះគឺអនុលោមទៅតាមមូលដ្ឋានគ្រឹះនៃគោលការណ៍ច្បាប់ ដែលចែងថា ជនណាក៏ដោយ ត្រូវតែជាមនុស្សគ្មានទោសរហូតទាល់តែជននោះត្រូវបានតុលាការជំនុំជម្រះ និងរកឃើញថាមានទោសពីបទឧក្រិដ្ឋណាមួយ។



រូបថត: អ.វ.ត.ក

*ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃប្រកាសសាលដីកាស្ថាពរសំណុំរឿង ០០ ១- ៣ កុម្ភៈ ២០១២*

## សំណួរទី ១៧ តើនរណាជាអ្នកសម្រេចថាជនណាខ្លះនឹងត្រូវនាំយកមកជំនុំជម្រះក្តី ហើយនឹងត្រូវចោទប្រកាន់ពីបទល្មើសអ្វី ?

អង្គជំនុំជម្រះវិសាមញ្ញមានសហព្រះរាជអាជ្ញាពីររូប ( កម្ពុជាមួយរូបនិងអន្តរជាតិមួយរូប ) ជាអ្នករៀបចំបញ្ជីឈ្មោះជនសង្ស័យនិងប្រមូលភ័ស្តុតាងបឋមនៃបទឧក្រិដ្ឋដែលត្រូវចោទថាបានប្រព្រឹត្ត។ សហព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿងក្តីទៅសហចៅក្រមស៊ើបអង្កេតពីររូប ( កម្ពុជាមួយរូបនិងអន្តរជាតិមួយរូប )។ សហចៅក្រមស៊ើបអង្កេតនឹងពិនិត្យពិច័យព័ត៌មានដែលទទួលបានពីសហព្រះរាជអាជ្ញា និងអនុវត្តកិច្ចស៊ើបសួរដោយឯករាជ្យនិងមិនលម្អៀងមុននឹងសម្រេចចោទប្រកាន់។ ប្រសិនបើការស៊ើបអង្កេតបង្ហាញភ័ស្តុតាងគ្រប់គ្រាន់ តុលាការនឹងបើកការជំនុំជម្រះក្តីលើសំណុំរឿងនោះ។

## សំណួរទី ១៨ តើនឹងមានអ្វីកើតឡើងប្រសិនបើសហព្រះរាជអាជ្ញា ឬក៏សហចៅក្រមស៊ើបអង្កេតមិនយល់ស្របគ្នាថាតើត្រូវបញ្ជូន ឬមិនបញ្ជូនរឿងក្តីទៅជំនុំជម្រះ ?

ទាំងសហព្រះរាជអាជ្ញាឬសហចៅក្រមស៊ើបអង្កេត នឹងព្យាយាមសម្រេចឱ្យបាននូវការព្រមព្រៀងគ្នា ប៉ុន្តែប្រសិនបើគាត់មិនអាចឈានដល់ការឯកភាពគ្នានោះទេ ពេលនោះចៅក្រម ៥ រូប នៃអង្គបុរេជំនុំជម្រះនឹងជួបជុំគ្នាដើម្បីពិនិត្យមើលថាតើត្រូវបញ្ជូនឬមិនបញ្ជូនរឿងក្តីទៅជំនុំជម្រះ។ ចៅក្រម ឬសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេតកម្ពុជាតែឯង ឬអន្តរជាតិតែឯង មិនអាចធ្វើឱ្យរាំងស្ទះដល់ការបញ្ជូនរឿងក្តីណាមួយទៅជំនុំជម្រះក្តីបានឡើយ។

## សំណួរទី ១៩ តើចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូងធ្វើការងារអ្វីខ្លះ ?

ចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង នឹងពិនិត្យភ័ស្តុតាងដែលដាក់ជូនដោយសហព្រះរាជអាជ្ញា ដោយមេធាវីចុងចោទ និងដោយជនរងគ្រោះដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ស្តាប់សេចក្តីថ្លែងការណ៍របស់ភាគីទាំងសងខាង បន្ទាប់មក ពិភាក្សាគ្នាថាតើជនសង្ស័យមានជាប់ពិរុទ្ធឬគ្មាន។ ចៅក្រមត្រូវចេញសេចក្តីសម្រេចចិត្តឬសាលក្រមមួយជាលាយលក្ខណ៍អក្សរដោយពន្យល់ពីហេតុផលនៃការវិនិច្ឆ័យដែលបានធ្វើឡើង។ ប្រសិនបើមានចៅក្រមណាម្នាក់មិនឯកភាពនឹងសាលក្រមនោះទេចៅក្រមនោះមានតួនាទីពន្យល់អំពីហេតុផល ដែលនាំឱ្យខ្លួនបោះឆ្នោតផ្សេងពីមតិភាគច្រើន។ រាល់ការវិនិច្ឆ័យឬសាលក្រមទាំងអស់ត្រូវផ្សព្វផ្សាយជាសាធារណៈ។

## សំណួរទី ២០ តើភ័ស្តុតាងអ្វីខ្លះនឹងត្រូវយកមកប្រើប្រាស់នៅក្នុងពេលជំនុំជម្រះក្តី ?

ភ័ស្តុតាងអាចត្រូវបានដាក់ជូនដោយ ចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង ដោយសហព្រះរាជអាជ្ញា ដោយមេធាវីការពារក្តី ឬដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ភ័ស្តុតាងទាំងនេះអាចជា៖

- ឯកសារ
- ភ័ស្តុតាងរូបវ័ន្ត ដូចជារណ្តៅសាកសពរួម ឬក៏អតីតគុក និង
- សេចក្តីថ្លែងការណ៍ និងកសិណសាក្សីជាជនរងគ្រោះ ឬជនដៃដល់ សាក្សី និងចុងចោទ


រូបថត: អ.វ.ត.ក

*សាធារណជនចូលរួមស្តាប់ការអានសេចក្តីសន្និដ្ឋានលើបទចោទប្រកាន់ក្នុងសំណុំរឿង ០០២ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២*

ឯកសាររាប់ពាន់សន្លឹកត្រូវបានប្រមូលចងក្រងទុក រណ្តៅសាកសពរួម គុក និងបូជនីយដ្ឋាន រាប់រយកន្លែង ត្រូវបានគេទៅពិនិត្យមើល និងផែនទីជាច្រើនត្រូវបានគូរដោយគណៈកម្មាធិការស្រាវជ្រាវរបស់រណសិរ្សនិងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងដោយកម្មវិធីស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ ភ័ស្តុតាងទាំងអស់នោះត្រូវបានផ្តល់ទៅឱ្យអង្គជំនុំជម្រះវិសាមញ្ញរួចហើយ។

នៅក្នុងតុលាការកម្ពុជា គ្រប់ភ័ស្តុតាងទាំងអស់ដែលប្រមូលបានដោយត្រឹមត្រូវតាមនីតិវិធីច្បាប់ អាចយកមកពិចារណាបាន។ វាអាស្រ័យទៅលើចៅក្រមជាអ្នកសម្រេចអំពីសារសំខាន់នៃភ័ស្តុតាងនីមួយៗ។

## សំណួរទី ២១ តើបទឧក្រិដ្ឋអ្វីនឹងត្រូវលើកយកមកជំនុំជម្រះ? តើការជំនុំជម្រះប្រើច្បាប់កម្ពុជាឬច្បាប់អន្តរជាតិ?

ប្រជាជនកម្ពុជាយ៉ាងហោចណាស់ ១,៧លាននាក់ បានស្លាប់ដោយទារុណកម្ម ការប្រហារជីវិត ការស្រេកឃ្លាន និងជំងឺដែលមិនមានការព្យាបាល ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ចៅក្រមចាំបាច់ត្រូវពិចារណាឱ្យបានច្បាស់លាស់ អំពីបទឧក្រិដ្ឋអ្វីដែលត្រូវបានប្រព្រឹត្តនៅពេលនោះនិងដោយនរណាខ្លះ។ការប្រឈមមុខនឹងការជំនុំជម្រះក្តីនេះនឹងអាស្រ័យទៅលើការប្រមែប្រមូលភ័ស្តុតាងឱ្យបានគ្រប់គ្រាន់ ដើម្បីរកឱ្យឃើញនូវទោសកំហុសរបស់បុគ្គលណាមួយដែលបានប្រព្រឹត្តបទឧក្រិដ្ឋ។

ទាំងបទឧក្រិដ្ឋនៅក្រោមច្បាប់ជាតិនិងច្បាប់អន្តរជាតិ ដូចខាងក្រោម អាចត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក៖

**បទឧក្រិដ្ឋនៅក្រោមច្បាប់កម្ពុជា ៖**

- អំពើមនុស្សឃាត
- ការធ្វើទារុណកម្ម
- ការធ្វើទុក្ខបុកម្នេញខាងសាសនា

**បទឧក្រិដ្ឋនៅក្រោមច្បាប់អន្តរជាតិ ៖**

- **អំពើប្រល័យពូជសាសន៍៖** ការសម្លាប់រង្គាល ការបង្កឱ្យមានរបួសផ្លូវកាយ ឬសតិបញ្ញា ក្នុងចេតនាបំផ្លាញទាំងស្រុងឬដោយផ្នែកនៃក្រុមជនជាតិ ជាតិពន្ធ ពូជសាសន៍ ឬសាសនាណាមួយ។
- **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖** អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ជាទាសករ ការនិរទេស ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទនិងទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទ។



*កៅអីទាំង ៤៨២ នៃសាលសវនាការនេះមានអ្នកចូលរួមអង្គុយពេញជាប្រចាំ នៅរៀងរាល់សវនាការ។ នេះគឺជាសាលសវនាការ*



រូបថត: អ.វ.ត.ក

ធំបំផុតក្នុងចំណោមសាលសវនាការរបស់តុលាការអន្តរជាតិទាំងអស់នៅលើសកលលោក ដែលគាំទ្រដោយ អ.ស.ប

- **ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ៖** ការប្រព្រឹត្តដោយខុសច្បាប់ទៅលើជនស៊ីវិល ឬឈ្លើយសឹក ការវាយប្រហារលើគោលដៅជនស៊ីវិល និងការបំផ្លាញស្ថាប័នអប់រំនិងសាសនា។
- **ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌៖** ការលួចឬបំផ្លិចបំផ្លាញអគារប្រវត្តិសាស្ត្រ ទីតាំងបុរាណ សារមន្ទីរ ស្នាដៃសិល្បៈឬប្រវត្តិសាស្ត្រ សៀវភៅសំខាន់ៗ និងបណ្ណាល័យ។
- **ឧក្រិដ្ឋកម្មប្រឆាំងបុគ្គល** ដែលត្រូវបានការពារដោយច្បាប់អន្តរជាតិ ( ដូចជាមន្ត្រីទូតជាដើម )។

## សំណួរទី ២២ តើចុងចោទមានសិទ្ធិអ្វីខ្លះ ?

ចុងចោទ (ជនត្រូវចោទ និង ជនជាប់ចោទ) មានសិទ្ធិការពារខ្លួននៅក្រោមច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ។ សិទ្ធិខ្លះនៃសិទ្ធិទាំងអស់នោះមាន៖

- សិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវនិងជាសាធារណៈ
- សិទ្ធិត្រូវបានគេសន្មតថាមិនមានកំហុស រហូតទាល់តែត្រូវបានតុលាការសម្រេចសេចក្តីថាមានទោស
- សិទ្ធិមានមេធាវីទៅតាមការជ្រើសរើសរបស់ខ្លួន ទោះជាមេធាវីនោះមានសញ្ជាតិខ្មែរឬបរទេស
- សិទ្ធិមានពេលវេលានិងសម្ភារៈគ្រប់គ្រាន់ដើម្បីឱ្យមេធាវីរៀបចំការពារក្តី
- សិទ្ធិទទួលបានមេធាវីពី អ.វ.ត.ក ប្រសិនបើចុងចោទមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីចំណាយទៅលើការជួលមេធាវី
- សិទ្ធិពិនិត្យសាក្សីដាក់បន្ទុកទៅលើរូបគាត់។

### សិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយត្រឹមត្រូវនិងយុត្តិធម៌

កតិកាសញ្ញាអន្តរជាតិស្ដីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ អនុវត្តបានចំពោះសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក។ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លើកបង្ហាញពីសិទ្ធិនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ដែលត្រូវបានអនុវត្តនៅ អ.វ.ត.ក ដូចជាសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌និងមិនលម្អៀង រួចផុតពីការជ្រៀតជ្រែកនយោបាយ សិទ្ធិនៃការសន្មតថាគ្មានទោស រហូតដល់តុលាការសម្រេចថាមានទោស និងសិទ្ធិទទួលបានមេធាវីតំណាងផលប្រយោជន៍។

## សំណួរទី ២៣ តើនរណាខ្លះនឹងត្រូវកោះអញ្ជើញឱ្យធ្វើជាសាក្សី?

សាក្សីគឺជាបុគ្គលដែលអាចផ្ដល់ព័ត៌មាន ឬរឿងរ៉ាវ ដោយផ្ទាល់និងពិតប្រាកដទាក់ទងនឹងការស៊ើបអង្កេត និងការជំនុំជម្រះក្ដីនានាដែលស្ថិតនៅក្នុងអាណត្តិរបស់តុលាការ។ អ្នកទាំងនោះអាចជាជនរងគ្រោះ ឬជាបុគ្គលណាម្នាក់ដែលមានព័ត៌មានទាក់ទងបទឧក្រិដ្ឋនោះ។រឿងរ៉ាវជាក់ស្ដែងដែលបុគ្គលនោះរៀបរាប់មានតម្លៃស្មើនឹងភ័ស្តុតាង។ ភ័ស្តុតាងដែលផ្ដល់ដោយសាក្សីក្នុងអំឡុងពេលស៊ើបអង្កេត នឹងក្លាយទៅជាផ្នែកមួយនៃសំណុំរឿង ឬប្រសិនបើត្រូវបានផ្ដល់ឱ្យក្នុងអំឡុងពេលជំនុំជម្រះក្ដី ភ័ស្តុតាងនោះនឹងក្លាយទៅជាឯកសារផ្លូវការនៃសវនាការ។ ជនណាក៏ដោយដែលត្រូវចាត់ទុកថាជាមនុស្សសំខាន់សម្រាប់ផ្ដល់ការពិតក្នុងពេលស៊ើបអង្កេតនិងពេលជំនុំជម្រះក្ដី អាចនឹងត្រូវសុំឱ្យផ្ដល់ភ័ស្តុតាង រាប់បញ្ចូលទាំងអ្នកជំនាញផងដែរ។

## សំណួរទី ២៤ តើខ្ញុំត្រូវផ្ដល់ព័ត៌មានទៅឱ្យតុលាការដែរឬទេ?

ប្រសិនបើព្រះរាជអាជ្ញា ឬចៅក្រមស៊ើបអង្កេត ចង់សម្ភាសន៍ជាមួយលោកអ្នកក្នុងករណីនេះលោកអ្នកត្រូវតែនិយាយការពិត។ទោះជាយ៉ាងណាក៏ដោយ លោកអ្នកមានសិទ្ធិនៅស្ងៀម ប្រសិនបើលោកអ្នកយល់ថាចម្លើយអាចធ្វើឱ្យលោកអ្នកមានជាប់ទាក់ទិននៅក្នុងបទឧក្រិដ្ឋនោះ។ ជាងនេះទៅទៀត លោកអ្នកមានសិទ្ធិស្នើសុំមេធាវី (ស្មាក្ដី) ដើម្បីផ្ដល់ការប្រឹក្សាដល់លោកអ្នក និងស្ថិតនៅជាមួយលោកអ្នកនៅក្នុងពេលសម្ភាសន៍។ (សម្រាប់ព័ត៌មានលម្អិត សូមអានទំព័រ *ប្រភពព័ត៌មាន*)។

## សំណួរទី ២៥ តើធ្វើយ៉ាងដូចម្ដេចប្រសិនបើខ្ញុំចង់ផ្ដល់ព័ត៌មានអំពីជនណាម្នាក់ដែលខ្ញុំជឿជាក់ថាបានប្រព្រឹត្តបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ?

ប្រសិនបើលោកអ្នកមានព័ត៌មាន ដែលអ្នកគិតថាវាអាចជួយដល់ព្រះរាជអាជ្ញា ឬអ្នកការពារក្ដី លោកអ្នកអាចទាក់ទងដោយផ្ទាល់ទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតាមរយៈអង្គការអន្តរការី (សូមអានទំព័រ *ប្រភពព័ត៌មាន*)។ ជនរងគ្រោះ ឬអ្នកផ្សេងទៀត ដែលមានព័ត៌មានទាក់ទិនអាចផ្ញើព័ត៌មាននេះទៅតុលាការ។ លោកអ្នកគួរតែបំពេញព័ត៌មាននៅលើទម្រង់បែបបទព័ត៌មានសម្រាប់ជនរងគ្រោះ ហើយផ្ញើទៅអង្គភាពគាំពារជនរងគ្រោះ។ (សូមអានសំណួរទី២៧)

## សំណួរទី ២៦ តើការគាំទ្រអ្វីខ្លះនឹងត្រូវផ្តល់ទៅឱ្យសាក្សីនិងជនរងគ្រោះ ដែលផ្តល់សក្ខីកម្ម និងសម្រាប់មនុស្សទូទាំងប្រទេស ដែលអាចនឹងមានការឈឺចាប់ក្នុងចិត្តនៅពេលស្តាប់ឮ សក្ខីកម្មដែលបានបង្ហាញនៅក្នុងតុលាការ ?

សាក្សីអាចទទួលរងការឈឺចាប់ក្នុងអារម្មណ៍ នៅពេលផ្តល់សក្ខីកម្ម អំពីបទពិសោធន៍របស់ខ្លួនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះ តុលាការរៀបចំផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រដល់សាក្សីទាំងឡាយ។ បុគ្គលដែលមិនត្រូវផ្តល់សក្ខីកម្ម ប៉ុន្តែត្រូវការការពិគ្រោះយោបល់និងការព្យាបាល គប្បីទាក់ទងគណៈកម្មាធិការសុខភាពផ្លូវចិត្តរបស់ក្រសួងសុខាភិបាល ដែលមានការិយាល័យនៅតាមបណ្តាខេត្តនានាទូទាំងប្រទេស ឬអង្គការក្រៅរដ្ឋាភិបាល ដែលជំនាញឯកទេសផ្នែកនេះ ដូចជាកម្មវិធីសុខភាពផ្លូវចិត្ត អង្គការចិត្តសង្គម-អន្តរវប្បធម៌ (TPO) ជាដើម។ (សូមអានទំព័រ *ប្រភពព័ត៌មាន*)។

## សំណួរទី ២៧ តើជនរងគ្រោះអាចចូលរួមក្នុងដំណើរការជំនុំជម្រះក្តីយ៉ាងដូចម្តេច ?

ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងទៅ ការិយាល័យសហព្រះរាជអាជ្ញា អំពីបទឧក្រិដ្ឋទាំងឡាយដែលពួកគាត់ជឿថាត្រូវបានប្រព្រឹត្ត។

ជនរងគ្រោះដែលទទួលការឈឺចាប់ទាំងផ្លូវកាយ ផ្លូវចិត្ត និងខូចខាតសម្ភារៈដោយសារតែឧក្រិដ្ឋកម្មដែលស៊ើបអង្កេតដោយតុលាការ អាចដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការជ្រើសរើសមេធាវីរបស់ខ្លួន។ បើសិនត្រូវការជំនួយ អ.វ.ត.ក នឹងជួយជនរងគ្រោះក្នុងការរៀបចំតំណាងរួមផ្នែកច្បាប់។ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចរៀបចំសកម្មភាពរបស់ខ្លួន ដោយចូលជាសមាជិកសមាគមជនរងគ្រោះ។ ក្នុងករណីដែលសំណុំរឿងត្រូវបញ្ជូនទៅជំនុំជម្រះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប (ជាតិមួយរូប និងអន្តរជាតិមួយរូប) នឹងសម្របសម្រួលក្នុងការធ្វើជាតំណាងផលប្រយោជន៍ឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

ជនរងគ្រោះដែលចង់ចូលរួមក្នុងដំណើរការតុលាការ ក្នុងនាមជាអ្នកប្តឹងធម្មតា ឬដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបំពេញទម្រង់បែបបទព័ត៌មាន ហើយផ្ញើទៅអង្គភាពគាំពារជនរងគ្រោះ។ សូមកត់សម្គាល់ផងដែរថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ បានបិទតាំងពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ ប៉ុន្តែលោកអ្នកនៅតែអាចដាក់ពាក្យបណ្តឹងបានគ្រប់ពេល។

ទម្រង់បែបបទនៃពាក្យបណ្តឹង អាចសុំពីអង្គភាពគាំពារជនរងគ្រោះ តាមអាសយដ្ឋានខាងក្រោម។ ទម្រង់បែបបទនេះក៏អាចទទួលយកបានពីគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.eccc.gov.kh និងនៅតាមបណ្តាអង្គការដៃគូនានា។ (សូមមើលទំព័រ *ប្រភពព័ត៌មាន*)

**អង្គភាពគាំពារជនរងគ្រោះ**
ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ២១៤ ២៩១

## សំណួរទី ២៨ តើជនរងគ្រោះមានសិទ្ធិទទួលសំណងដែរឬទេ?

ប្រសិនបើជនជាប់ចោទត្រូវបានផ្តន្ទាទោសដោយ អ.វ.ត.ក ជនរងគ្រោះអាចស្នើសុំទៅតុលាការឱ្យចេញដីកាបង្គាប់ឱ្យមានការសងសំណង។

នៅក្រោមច្បាប់កម្ពុជាបច្ចុប្បន្ន ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចទាមទារសំណងក្នុងករណីបណ្តឹងព្រហ្មទណ្ឌដែលគាត់បានរងគ្រោះ។ ចៅក្រមបានសម្រេចថា អង្គជំនុំជម្រះវិសាមញ្ញមិនអាចផ្តល់សំណងជាថវិកាបានឡើយ ដោយហេតុថាជនរងគ្រោះមានចំនួនច្រើនលើសលប់។ ប៉ុន្តែជនរងគ្រោះអាចទទួលសំណងសមូហភាពនិងសំណងផ្លូវចិត្ត ដូចជា ការតម្រូវឱ្យផ្សព្វផ្សាយជាសាធារណៈនូវសាលក្រម ដោយចំណាយថវិការបស់ជនជាប់ចោទ ឬតុលាការអាចបញ្ជាឱ្យផ្តល់ថវិកាសម្រាប់សកម្មភាព ឬសេវាកម្មនានា ដែលមិនរកប្រាក់ចំណេញ ហើយដែលសកម្មភាពឬសេវាទាំងនោះគឺដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះទូទៅ។



រូបថត: អ.វ.ត.ក

អ្នករស់រានមានជីវិតពីគុកទួលស្លែង លោក ជុំ ម៉ី (កណ្តាល) និងលោក ប៊ូ ម៉េង (ខាងស្តាំ) លើកសៀវភៅសាលដីកាស្តាពរសំណុំរឿង ០០១ ប្រឆាំងនឹងអតីតប្រធានគុកឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច

## ការចូលរួមរបស់ជនរងគ្រោះ

អង្គភាពគាំពារជនរងគ្រោះត្រូវបានបង្កើតឡើង ដើម្បីជួយជនរងគ្រោះដែលចង់ចូលរួមក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ។ អង្គភាពគាំពារជនរងគ្រោះគឺជាមជ្ឈមណ្ឌលកណ្តាល សម្រាប់ទាក់ទងរវាងអង្គជំនុំជម្រះនិងជនរងគ្រោះ ឬតំណាងរបស់ពួកគាត់។ អង្គភាពគាំពារជនរងគ្រោះត្រូវផ្តល់ព័ត៌មានជូនដល់ជនរងគ្រោះ អំពីសិទ្ធិរបស់គាត់ក្នុងការចូលរួមនិងការទទួលសំណង និងជួយដល់គាត់ក្នុងការសរសេរពាក្យបណ្តឹងនិងទម្រង់បែបបទសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីផ្ញើទៅ អ.វ.ត.ក ប្រសិនបើពួកគាត់ចង់ធ្វើដូច្នេះ។ អង្គភាពគាំពារជនរងគ្រោះជួយគាំទ្រដល់ការងាររបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ដោយរៀបចំបែបបទធ្វើពាក្យបណ្តឹង និងពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី។ ក្រៅពីនេះ អង្គភាពក៏ជួយរក្សាទំនាក់ទំនងរវាងជនរងគ្រោះនិងមេធាវីរបស់គាត់ ជួយសម្រួលការងារទាក់ទងនឹងពាក្យបណ្តឹងនិងពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី និងជួយផ្តល់ព័ត៌មានទាន់ហេតុការណ៍នានាទាក់ទិននឹងការវិវឌ្ឍនៃរឿងក្តីនីមួយៗ។ អង្គភាពនេះក៏នឹងជួយដល់ជនរងគ្រោះដើម្បីទទួលបានសេវាកម្មផ្នែកច្បាប់ ក៏ដូចជាសេវាគាំទ្រផ្លូវចិត្តជាដើម។ អង្គភាពគាំពារជនរងគ្រោះ ក៏ធ្វើការងារជាមួយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីផ្តល់ជំនួយគាំទ្រដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងក្នុងដំណាក់កាលសវនាការនិងក្រោយពេលសវនាការ។



## សំណួរទី ២៩ ហេតុអ្វីបានជាអង្គការសហប្រជាជាតិចូលរួមក្នុងដំណើរការនេះ ?

នៅខែមិថុនា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រី គឺសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន បានផ្ញើសារលិខិតមួយជូនលោក កូហ្វី អាណាន់ ដែលពេលនោះជាអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ក្នុងដំណើរការជំនុំជម្រះក្តីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សហនាយករដ្ឋមន្ត្រីបានស្នើសុំជំនួយឧបត្ថម្ភខាងលើ ដោយយល់ឃើញថាវិស័យតុលាការនៅកម្ពុជានៅមានកង្វះខាតធនធាននិងជំនាញក្នុងការបំពេញភារកិច្ចដ៏ស្មុគស្មាញជាពិសេសដោយសារឧក្រិដ្ឋកម្មដែលកើតឡើងមានទំហំធំធេង។

អង្គការសហប្រជាជាតិផ្តល់ជំនួយបច្ចេកទេសដល់ អ.វ.ត.ក តាមរយៈការជួយរៀបចំនិងជ្រើសរើសចៅក្រមនិងបុគ្គលិកអន្តរជាតិ តាមរយៈជំនួយអង្គការសហប្រជាជាតិសម្រាប់សាលាក្តីខ្មែរក្រហម (UNAKRT)។

## សំណួរទី ៣០ ហេតុអ្វីបានជាអតីតមេដឹកនាំខ្មែរក្រហមមិនត្រូវបានយកទៅជំនុំជម្រះក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) នៅទីក្រុងឡាអេ ឬក្នុងតុលាការយុត្តិធម៌អន្តរជាតិ(ICJ) ?

តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ត្រូវបានបង្កើតឡើងនៅទីក្រុងឡាអេប្រទេសហូឡង់ នៅឆ្នាំ២០០២។ កម្ពុជាក៏ជាសមាជិកហត្ថលេខីរបស់តុលាការនេះដែរ។ ក៏ប៉ុន្តែ តុលាការនេះអាចបើកសវនាការនិងដោះស្រាយតែករណីដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅក្រោយពេលបង្កើតតុលាការនេះតែប៉ុណ្ណោះ។ រីឯតុលាការយុត្តិធម៌អន្តរជាតិជំនុំជម្រះក្តីតែសំណុំរឿងរវាងរដ្ឋនិងរដ្ឋតែប៉ុណ្ណោះ។



ប្រភព: អង្គការសហប្រជាជាតិ

ឯកឧត្តម សុខ អាន ដែលកាលនោះជាទេសរដ្ឋមន្ត្រី ជួបជាមួយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ នៅខែមករា ឆ្នាំ២០០៣ ដើម្បីពិភាក្សាអំពីការបង្កើតតុលាការខ្មែរក្រហម

## សំណួរទី ៣១ តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាតុលាការកម្ពុជាឬជាតុលាការអន្តរជាតិ ?

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្ថិតក្នុងប្រព័ន្ធតុលាការកម្ពុជា។ ទោះជាយ៉ាងនេះក្តីតុលាការនេះមានលក្ខណៈពិសេសជាតុលាការ"កូនកាត់"។ បុគ្គលិកក្នុងតុលាការរួមមាន ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារក្តីទាំងជាតិ និងអន្តរជាតិ។ ទោះជាយ៉ាងណា មន្ត្រីភាគច្រើនបម្រើការនៅក្នុងតុលាការនេះគឺបុគ្គលិកកម្ពុជា។ ទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិ នឹងត្រូវយកមកប្រើប្រាស់ក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ។

## សំណួរទី ៣២ តើមានតុលាការផ្សេងទៀតនៅក្នុងពិភពលោកដែលមានលក្ខណៈដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ?

តុលាការកូនកាត់ប្រភេទនេះត្រូវបានបង្កើតឡើងនាពេលកន្លងទៅថ្មីៗនេះនៅក្នុងប្រទេសមួយចំនួនរួមមាន សៀរ៉ាឡេអូន ទីម័រខាងកើត កូសូវ៉ូ និង បូស្នៀ ប៉ុន្តែតុលាការនីមួយៗមានចរិតលក្ខណៈដោយឡែកៗពីគ្នា។

## សំណួរទី ៣៣ តើហេតុអ្វីបានជាតុលាការប្រភេទនេះត្រូវបានយកមកប្រើសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ?

គំរូតុលាការកូនកាត់នេះត្រូវបានគេមើលឃើញ ថាជាមធ្យោបាយមួយដើម្បីផ្តល់ឱកាសឱ្យមានការចូលរួមពេញទំហឹង ពីសំណាក់ប្រជាជនកម្ពុជា ហើយទន្ទឹមនឹងនេះ ធានាឱ្យបានតាមបទដ្ឋានអន្តរជាតិ។ មិនដូចជាសាលាក្តីសម្រាប់ប្រទេសរ៉្វាន់ដា ឬសាលាក្តីសម្រាប់អតីតប្រទេសយូហ្គោស្លាវីឡើយ ការជំនុំជម្រះក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធ្វើឡើងមិនឆ្ងាយពីទីកន្លែងបទឧក្រិដ្ឋបានកើតឡើងឡើយ។ អង្គជំនុំជម្រះនេះប្រព្រឹត្តទៅនៅប្រទេសកម្ពុជា ហើយដំណើរការជំនុំជម្រះក្តីត្រូវធ្វើឡើងភាគច្រើនជាភាសាខ្មែរ និងបើកចំហឱ្យមានការចូលរួមពីប្រជាជនកម្ពុជា និងត្រូវបានផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងសារព័ត៌មាននានា។

## សំណួរទី ៣៤ តើត្រូវចំណាយថវិកាប៉ុន្មានសម្រាប់ដំណើរការជំនុំជម្រះក្តីនេះ ?

ការចំណាយសម្រាប់ដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ពីឆ្នាំ២០០៦ រហូតដល់ចុងខែធ្នូ ឆ្នាំ២០១៤ មានចំនួន ២៣២,៤ លានដុល្លារអាមេរិក។គម្រោងថវិកាសម្រាប់ឆ្នាំ២០១៥គឺ៣៣,៨លានដុល្លារ (សូមមើលគម្រោងថវិការបស់ អ.វ.ត.ក)

| គម្រោងថវិកាអ.វ.ត.ក | ភាគីជាតិ | ភាគីអន្តរជាតិ | សរុប |
|---|---|---|---|
| ការចំណាយឆ្នាំ ២០០៦-២០១៤ | ៥៥,៧ លាន ដុល្លារអាមេរិក | ១៥៤,៩ លាន ដុល្លារអាមេរិក | ២៣២,៤ លាន ដុល្លារអាមេរិក |
| គម្រោងថវិកា ឆ្នាំ២០១៥ | ៦,៧ លាន ដុល្លារអាមេរិក | ២៧,១ លាន ដុល្លារអាមេរិក | ៣៣,៨ លាន ដុល្លារអាមេរិក |



រូបថត: អ.វ.ត.ក

*គណៈប្រតិភូក្រុមប្រទេសម្ចាស់ជំនួយធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។*

## សំណួរទី ៣៥ តើតុលាការនេះទទួលថវិកាមកពីប្រភពណា ?

រដ្ឋាភិបាលជាង៣០ប្រទេសបានចូលរួមជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់វិភាគទានស្ម័គ្រចិត្តសម្រាប់គាំទ្រតុលាការនេះ។

ប្រទេសជប៉ុនបានផ្តល់ថវិកាជិត ៣៥ ភាគរយនៃប្រាក់វិភាគទានដែលជាជំនួយអន្តរជាតិ ក្រៅពីនេះ មានប្រទេសម្ចាស់ជំនួយធំៗ ដូចជា សហរដ្ឋអាមេរិក ប្រទេសអូស្ត្រាលី អាល្លឺម៉ង់ ចក្រភពអង់គ្លេស និងសហភាពអឺរ៉ុប។ រាជរដ្ឋាភិបាលកម្ពុជា ក៏បានផ្តល់វិភាគទានចំនួន ១៨,៥ លានដុល្លារអាមេរិក ហើយនៅមានថវិកាចំនួន ៥,៤លានដុល្លារអាមេរិក ដែលនៅសល់ពីសម័យអ៊ុនតាក់ (UNTAC) ផង។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់វិភាគទានជាសម្ភារៈដូចជាផ្តល់ទីកន្លែងសម្រាប់ធ្វើការ មន្ទីរឃុំឃាំង និងសេវាផ្សេងៗទៀត។

រហូតមកដល់ពេលនេះ នៅតែមានតម្រូវការជាបន្ទាន់ក្នុងការប្រមូលថវិកាសម្រាប់បន្តដំណើរការងាររបស់សាលាក្តីនេះ។ យើងរំពឹងថានឹងបន្តទទួលបាននូវការគាំទ្រនិងផ្តល់ថវិកាពីប្រទេសផ្តល់ជំនួយ ឬពីអង្គការ ក្រុមហ៊ុន មូលនិធិ ឬបុគ្គលនានា។


រូបថត: អ.វ.ត.ក

*ប្រជាពលរដ្ឋមកពីខេត្តបាត់ដំបងធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។*

## សំណួរទី ៣៦ តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពីរឿងខ្មែរក្រហម និងដំណើរការកាត់ក្តីទាំងនេះដោយវិធីណា ?

ផ្នែកកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាកន្លែងដែលត្រូវទាក់ទងមុនគេសម្រាប់ព័ត៌មានអំពីតុលាការ។

សូមទាក់ទងផ្នែកកិច្ចការសាធារណៈតាមរយៈ
សារអេឡិចត្រូនិកៈ pas@eccc.gov.kh
ទូរស័ព្ទៈ +៨៥៥ (០២៣) ៨៦១ ៥០០
ទូរសារៈ +៨៥៥ (០២៣) ៨៦១ ៥៥៥
គេហទំព័រៈ http://www.eccc.gov.kh/

ប្រព័ន្ធសារព័ត៌មាននិងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ក៏ផ្តល់ព័ត៌មានស្តីពី អ.វ.ត.ក ដែរ។ (សូមអានទំព័រ *ប្រភពព័ត៌មាន*)


រូបថត: អ.វ.ត.ក

*អ្នកសារព័ត៌មានជាតិនិងអន្តរជាតិ តាមដាននិងផ្សព្វផ្សាយជាប្រចាំអំពីដំណើរការនៃ អ.វ.ត.ក*




*អ.វ.ត.ក នៅលើកញ្ចក់ទូរទស្សន៍៖ មន្ត្រីតុលាការនិងផ្នែកពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០២ នៅក្នុងកិច្ចពិភាក្សាតុមូលនៅក្នុងស្ទូឌីយោ ទូរទស្សន៍ជាតិកម្ពុជា មុនពេលប្រកាសសាលក្រមលើសំណុំរឿង ០០២/០១* រូបថត៖ អ.វ.ត.ក

## សំណួរទី ៣៧ តើអង្គការក្រៅរដ្ឋាភិបាលមានតួនាទីអ្វីខ្លះ?

អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិជាច្រើន ចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម។ ការគាំទ្ររបស់ពួកគេរួមមានការផ្តល់ការពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រដល់សាក្សីនិងជនរងគ្រោះ និងការផ្តល់ព័ត៌មាន ឬការផ្តល់ការប្រឹក្សាច្បាប់ និងការធ្វើជាតំណាងជនរងគ្រោះ។ អង្គការទាំងនោះក៏បានធ្វើការងារផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់សាធារណជនអំពីដំណើរការរបស់អ.វ.ត.ក។ (សូមអានទំព័រ *ប្រភពព័ត៌មាន*)

## សំណួរទី ៣៨ តើខ្ញុំអាចស្វែងរកសេវាកម្មគាំទ្រសម្រាប់រូបខ្ញុំនៅទីណា?

ផ្នែកគាំពារជនរងគ្រោះ និងអង្គភាពគាំពារសាក្សី/អ្នកជំនាញ ផ្តល់ជំនួយជាច្រើនដល់សាក្សីនិងអ្នកជំនាញ។ ខណៈដែលរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ផ្តល់សេវាកម្មសុខភាពផ្លូវចិត្ត អង្គការក្រៅរដ្ឋាភិបាលនិងសមាគមមួយចំនួនទៀត ផ្តល់ជំនួយផ្លូវច្បាប់ និងសេវាកម្មផ្សព្វផ្សាយព័ត៌មាន។ (សូមអានទំព័រ *ប្រភពព័ត៌មាន*)













*ប្រជាជនកម្ពុជានៅទូទាំងប្រទេសស្វែងយល់អំពីដំណើរការរបស់ អ.វ.ត.ក តាមរយៈកម្មវិធីផ្សព្វផ្សាយរបស់តុលាការនេះ។ ប្រជាជនជាង ៣៥.០០០នាក់ បានមកចូលរួមស្តាប់សវនាការក្នុងសំណុំរឿង ០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច ហើយជាង ១៣២ ៣៧២ នាក់ ផ្សេងទៀត បានចូលរួមតាមដានសវនាការក្នុងសំណុំរឿង ០០២ ពីខែវិច្ឆិកា ឆ្នាំ២០១១ ដល់ចុងខែមិថុនា ឆ្នាំ២០១៥។ ជាងនេះទៅទៀត ប្រជាជនកម្ពុជារាប់ម៉ឺននាក់បានចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សាដែលរៀបចំដោយ អ.វ.ត.ក តាំងពីឆ្នាំ២០០៩។ អ.វ.ត.ក ក៏បានចុះផ្សព្វផ្សាយដល់សាលារៀននានានៅទូទាំងប្រទេស អំពីដំណើរការរបស់សាលាក្តី។*

# ប្រភពព័ត៌មានទាក់ទងនឹង អ.វ.ត.ក

## ប្រព័ន្ធផ្សព្វផ្សាយ

### តាមរយៈការអានឯកសារ

កាសែតក្នុងស្រុកទាំងអស់តែងតែបោះពុម្ពផ្សាយអត្ថបទទាក់ទិននឹងការវិវឌ្ឍនៃ អ.វ.ត.ក ជាប្រចាំ។ អ.វ.ត.ក ក៏បានចេញផ្សាយព្រឹត្តិប័ត្រព័ត៌មានប្រចាំខែតាមប្រព័ន្ធអ៊ីនធឺណិតដែលអាចអានបាននៅគេហទំព័រ អ.វ.ត.ក www.eccc.gov.kh។

ឯកសារទាំងប៉ុន្មានដែលបោះពុម្ពផ្សាយដោយ អ.វ.ត.ក រួមទាំងសៀវភៅសាលក្រមនិងសាលដីកាស្ថាពរក្នុងសំណុំរឿង០០១ អាចរកអានបាននៅតាមបណ្ណាល័យ មហាវិទ្យាល័យនិងសាកលវិទ្យាល័យ និងសាលាឃុំ/ស្រុក/ខ័ណ្ឌ/ខេត្ត/ក្រុង ទូទាំងប្រទេស។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតបណ្ណាល័យសាធារណៈមួយនៅរាជធានីភ្នំពេញ ដែលប្រជាជនអាចមកស្វែងយល់ព័ត៌មានតាមរយៈឯកសារ សៀវភៅ រូបថត ទស្សនាវដ្តី និងវីដេអូ ដែលទាក់ទងនឹងប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ។

មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានបោះពុម្ពផ្សាយសៀវភៅនិងទស្សនាវដ្ដីស្វែងរកការពិតសម្រាប់ចែកផ្សាយទូទាំងប្រទេស។

អង្គការ Asian International Justice Initiative (AIJI) ដែលកើតចេញពីកិច្ចសហប្រតិបត្តិការរវាងអង្គការ East-West Center នៃសាកលវិទ្យាល័យហាវ៉ៃ និងមជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាមនៃសាកលវិទ្យាល័យកាលីហ្វ័រញ៉ា នៅ ប៊ឺកគ្លី បានបោះពុម្ពផ្សាយរបាយការណ៍ប្រចាំសប្តាហ៍ជាភាសាខ្មែរនិងភាសាអង់គ្លេស ដែលមានឈ្មោះថា "ការឃ្លាំមើលសាលាក្តីខ្មែរក្រហម" ( KRT Trial Monitor ) ដែលផ្តល់ព័ត៌មានសង្ខេបនិងការវិភាគផ្លូវច្បាប់ទៅលើដំណើរការតុលាការ។

### តាមរយៈអ៊ីនធឺណិត

លោកអ្នកអាចស្វែងរកព័ត៌មានទាន់ហេតុការណ៍ទាក់ទងនឹងដំណើរការរបស់ អ.វ.ត.ក តាមរយៈគេហទំព័រ៖ www.eccc.gov.kh។ អត្ថបទ រូបភាពនិងវីដេអូទាន់ហេតុការណ៍ ក៏អាចរកមើលបានក្នុងបណ្តាញទំនាក់ទំនងសង្គមដូចជា៖

Facebook: www.facebook.com/krtribunal

YouTube: www.youtube.com/krtribunal

Flickr: www.flickr.com/krtribunal

Twitter: twitter.com/krtribunal

សូមអាននៅគេហទំព័រ www.unakrt-online.org សម្រាប់ព័ត៌មានទាក់ទងនឹងជំនួយអង្គការសហប្រជាជាតិដល់ អ.វ.ត.ក។

មានការផ្សាយ Webcast នៃដំណើរការនីតិវិធីតុលាការនៅលើគេហទំព័រ www.cambodiatribunal.org។

មានគេហទំព័រមួយចំនួនទៀតដែលផ្សាយព័ត៌មានអំពីស អ.វ.ត.ក ដូចជា ៖

**មជ្ឈមណ្ឌលឯកសារកម្ពុជា** www.dccam.org

**Asian International Justice Initiative (AIJI)**
www.krtmonitor.org
Twitter: www.twitter.com/krt_monitor
Facebook: www.facebook.com/krttrialmonitor

**ក្រុមតាមដានអំពើប្រល័យពូជសាសន៍** www.genocidewatch.org នៃកម្មវិធីស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជា របស់សាកលវិទ្យាល័យ យែល www.yale.edu.org។ កម្មវិធីឃ្លាំមើលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ www.genocidewatch.org

## តាមរយៈវិទ្យុ

**វិទ្យុជាតិកម្ពុជា** (FM ៩៦ FM ១០៥.៧៥ និង AM ៩១៨) ព្រមទាំងស្ថានីយ៍វិទ្យុឯកជន និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ធ្វើសេចក្តីរាយការណ៍ព័ត៌មានជាទៀងទាត់អំពីដំណើរការជំនុំជម្រះក្តីរបស់ អ.វ.ត.ក។ ខាងក្រោមនេះជាកម្មវិធីមួយចំនួន៖

**កម្មវិធីវិទ្យុប្រចាំសប្តាហ៍** "*ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម*" របស់ អ.វ.ត.ក ដែលផ្សាយរៀងរាល់ថ្ងៃព្រហស្បតិ៍ វេលាម៉ោង ១២ថ្ងៃត្រង់ ដល់ ១រសៀល នៅស្ថានីយ៍វិទ្យុបាយ័ន FM ៩៥។ សាធារណជនអាចទូរស័ព្ទចូលដើម្បីបញ្ចេញយោបល់និងសួរសំណួរ តាមលេខទូរស័ព្ទ ០១២ ៩៩៩ ០៩៥/ ០១៥ ៥៥០២៩៥/ ០៩៧ ៧០៩០៧៥១។

**មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)**
ផ្សាយជាទៀងទាត់នូវព័ត៌មានទាក់ទងនឹងអ.វ.ត.ក។

**គណៈកម្មាធិការប្រព្រឹត្តកម្មការពារសិទ្ធិមនុស្សនៅកម្ពុជា (CHRAC)** បង្កើត" កម្មវិធីឃ្លាំមើលដំណើរការសាលាក្តីខ្មែរក្រហម " ដែលផ្សាយតាមវិទ្យុ FM ១០២ (វិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា)៖
- ថ្ងៃចន្ទក្នុងសប្តាហ៍ទី១ ឬទី២ នៅខែនីមួយៗដោយធ្វើការផ្សាយផ្ទាល់ពីម៉ោង ១៦:១០-១៧ម៉ោ។
- ផ្សាយឡើងវិញនៅថ្ងៃអង្គារ ពីម៉ោង ១៨:៣០-១៩ម៉ោ (មួយសប្តាហ៍បន្ទាប់ពីការផ្សាយផ្ទាល់)

**វិទ្យុអាស៊ីសេរី (RFA)** ផ្សាយជាភាសាខ្មែរតាមរយៈ
- វិទ្យុ AM ១៣.៨៦៥ KHz និង AM ១៥.៧៨៥ KHz ម៉ោង ៧:៣០-៨:៣០ យប់
- វិទ្យុ AM ៧.៥៨០ KHz និង AM ១៣.៧៤០ KHz ម៉ោង ៥:៣០-៦:៣០ ព្រឹក
- វិទ្យុ FM ១០៥ ម៉ោង ៦:០០ - ៧:០០ ព្រឹក និង ម៉ោង ៨:៣០ - ៩:៣០ យប់
- វិទ្យុ FM ១០២ ម៉ោង ៧:០០ - ៨:០០ ព្រឹក និង ម៉ោង ១០:៣០ - ១១:៣០ យប់
- វិទ្យុ FM ៩៣.៥ ម៉ោង ៦:០០ - ៧:០០ ព្រឹក និងម៉ោង ៨:០០ - ៩:០០ យប់

**វិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA)** ផ្សាយជាភាសាខ្មែរតាមរយៈ៖
- វិទ្យុ AM ១៥៧៥, AM៦០៦០, AM ៧១៣០ និង AM ១៥៣៤០ ម៉ោង ៥:០០ - ៥:៣០ ព្រឹក
- វិទ្យុ AM ១៥៧៥, AM ៥៩៥៥ និង AM ៧១៥៥ ម៉ោង ៨:៣០ - ៩:៣០ យប់
- វិទ្យុ FM ១០៥ ម៉ោង ៧:០០ - ៧:៣០ ព្រឹក និងម៉ោង ៩:៣០ - ១០:៣០ យប់
- វិទ្យុ FM ៩៣.៥ ម៉ោង ៥:៣០ - ៦:០០ ព្រឹក
- វិទ្យុ FM ១០២ ម៉ោង ៦:០០ - ៦:៣០ ព្រឹក និងម៉ោង ៨:៣០ - ៩:៣០ យប់

**វិទ្យុអូស្ត្រាលី ABC** ផ្សាយហើយផ្សាយជាភាសាអង់គ្លេស ២៤ ម៉ោងក្នុងមួយថ្ងៃ តាមរយៈវិទ្យុ FM ១០១.៥ នៅភ្នំពេញ និងខេត្តសៀមរាប។

**វិទ្យុបារាំងអន្តរជាតិ (RFI)** ផ្សាយជាភាសាខ្មែរ ម៉ោង ៧:០០-២០:០០ យប់ តាមរយៈវិទ្យុ៖
- វិទ្យុ FM ៩២ ភ្នំពេញ
- វិទ្យុ FM ៩២ ខេត្តសៀមរាប
- វិទ្យុ FM ៩៤.៥ ខេត្តបាត់ដំបង
- វិទ្យុ FM ៩៤.៥ ខេត្តកំពង់ចាម
- វិទ្យុ FM ៩៤.៥ ក្រុងព្រះសីហនុ
- វិទ្យុ FM ១០២ ភ្នំពេញ ម៉ោង ៩:៣០ - ១០:៣០

យប់  និងផ្សាយជាភាសាបារាំង ២៤ ម៉ោងក្នុងមួយថ្ងៃ តាមរយៈវិទ្យុ FM ៩២ នៅភ្នំពេញ។

## តាមរយៈទូរទស្សន៍

ស្ថានីយ៍ទូរទស្សន៍ក្នុងស្រុកជាច្រើនផ្សាយព័ត៌មានជាទៀងទាត់អំពីដំណើរវិវឌ្ឍន៍របស់ អ.វ.ត.ក ក្នុងនាទីព័ត៌មានឬកម្មវិធីសាធារណៈរបស់ខ្លួន រួមមាន៖ ទូរទស្សន៍ស៊ីធីអិន ទូរទស្សន៍ជាតិកម្ពុជា ទូរទស្សន៍អប្សរា ទូរទស្សន៍បាយ័ន ទូរទស្សន៍លេខ៩ ទូរទស្សន៍អាស៊ី-អគ្នេយ៍ និងទូរទស្សន៍ហង្សមាស ទូរទស្សន៍ភីអិនអិន។ ទូរទស្សន៍អន្តរជាតិមួយចំនួន ដូចជា ទូរទស្សន៍ BBC ទូរទស្សន៍ Al Jazeera ទូរទស្សន៍ CNN  ទូរទស្សន៍NHK ទូរទស្សន៍ Channel News Asia ក៏ផ្សព្វផ្សាយអំពី ព័ត៌មានទាន់ហេតុការណ៍នៅ អ.វ.ត.ក ដែរ។ ទូរទស្សន៍ជាតិកម្ពុជាតែងតែធ្វើការផ្សាយផ្ទាល់ពីព្រឹត្តិការណ៍សំខាន់ទាក់ទងនឹងតុលាការ។

## អង្គការដែលផ្តល់ព័ត៌មានជាសាធារណៈ

### Asian International Justice Initiative (AIJI)

ផ្ទះលេខ១៩៩ ជាន់ទីពីរ ផ្លូវលេខ ៣០៦ កែងផ្លូវ ៦៣ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ភ្នំពេញ
សារអេឡិកត្រូនិក: aiji.krtmonitoring@gmail.com
គេហទំព័រ: www.krtmonitor.org
http://forum.eastwestcenter.org/Khmer-Rouge-Trials/
http://socrates.berkeley.edu/~warcrime/
និងក្នុងបណ្តាញទំនាក់ទំនងសង្គម: @KRT_Monitor on Twitter; KRT Trial Monitor on Facebook

AIJI ក៏បោះពុម្ពផ្សាយ "របាយការណ៍តាមដានតុលាការខ្មែរក្រហម" ប្រចាំសប្តាហ៍ជាភាសាខ្មែរនិងអង់គ្លេស ដែលផ្តល់ព័ត៌មានសង្ខេបនិងការវិភាគលើដំណើរការនីតិវិធីនៅ អ.វ.ត.ក។ សាធារណជនអាចអានរបាយការណ៍នេះនៅក្នុងគេហទំព័ររបស់ AIJI ឬអាចស្នើសុំតាមរយៈសារអេឡិចត្រូនិក។ AIJI ក៏ផ្តល់ព័ត៌មានអំពីការវិវត្តថ្មីៗបំផុតនៃដំណើរការ អ.វ.ត.ក នៅលើបណ្តាញសង្គម Twitter និង Facebook។

### មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា

ផ្ទះលេខ ៦៤ ផ្លូវលេខ ២០០ ឧកញ៉ាម៉ែន សង្កាត់បឹងរាំង ខណ្ឌដូនពេញ ភ្នំពេញ ១២២១១ កម្ពុជា
ទូរស័ព្ទ : ០២៣ ៩៩២ ១៧៤
សារអេឡិចត្រូនិក: archives@bophana.org.kh / archives@bophana.org
គេហទំព័រ៖ www.bophana.org

### គណៈកម្មាធិការប្រព្រឹត្តិកម្មនៃសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)

ផ្ទះលេខ ៩ ផ្លូវលេខ ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន
ប្រអប់សំបុត្រលេខ: ៤៩៩ ភ្នំពេញ
ទូរស័ព្ទនិងទូរសារ: ០២៣ ៣០១ ៤១៥
សារអេឡិចត្រូនិក: chrac@forum.org.kh

### សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

ផ្ទះលេខ ៣ ផ្លូវលេខ ១៥៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទនិងទូរសារ: ០២៣ ៩៩០ ៥៤៤
សារអេឡិចត្រូនិក: adhoc@forum.org.kh
គេហទំព័រ: www.adhoc-cambodia.org/

### គម្រោងយុត្តិធម៌សង្គមសេរី (CJI/OSJI)

មណ្ឌលភ្នំពេញ ជាន់ទី២ បន្ទប់លេខ ២២២ ភ្នំពេញ
ទូរស័ព្ទ និងទូរសារ: ០២៣ ២២១ ៧៩៣
សារអេឡិចត្រូនិក: cji@online.com.kh
គេហទំព័រ: www.babcambodia.org.cji

**មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)**
ផ្ទះលេខ ៦៦C មហាវិថីព្រះសីហនុ ភ្នំពេញ
ទូរស័ព្ទ: ០២៣ ២១១ ៨៧៥
ទូរសារ: ០២៣ ២១០ ៣៥៨
សារអេឡិចត្រូនិក: dccam@online.com.kh
គេហទំព័រ: www.dccam.org

**មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការផ្សះផ្សានៅកម្ពុជា (ICFC)**
ផ្ទះលេខ ៩៦ មហាវិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ៦៩៥ ៦៥ ១២ / ៥៥៥ ០៩ ២៥
សារអេឡិចត្រូនិច: Cambodia@centerforconciliation.org
គេហទំព័រ: www.centerforconciliation.org

**វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID)**
ផ្ទះលេខ ៦Z មហាវិថីម៉ៅសេទុង
សង្កាត់បឹងកេងកង១ រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ២១៤ ៩២៨
ទូរសារ: ០២៣ ២១៦ ២០៦
សារអេឡិចត្រូនិក: trainner.kid@online.com.kh
គេហទំព័រ: www.kidcambodia.org

**មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)**
ផ្ទះលេខ ៣០ ផ្លូវលេខ ៤៨៨ /៤៨៤ ភ្នំពេញ
ទូរស័ព្ទនិងទូរសារ: ០២៣ ២២៣ ៥៩៧
សារអេឡិចត្រូនិក: fm102@wmc.org.kh
គេហទំព័រ: www.wmc.org.kh

**អង្គការយុវសន្តិភាព (YFP)**
ផ្ទះលេខ ៤-៦ G ផ្លូវលេខ ៥១៣ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ភ្នំពេញ
ទូរស័ព្ទនិងទូរសារ: ០២៣ ៨៨១ ៣៤៦
សារអេឡិចត្រូនិក: admin@yfpcambodia.org
គេហទំព័រ: www.yfpcambodia.org

## អង្គការដែលផ្តល់ការគាំទ្រនិងផ្តល់ជំនួយផ្នែកច្បាប់

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BACK)**
ផ្ទះលេខ ១០-១១ ផ្លូវកាកបាទក្រហមខ្មែរ (ផ្លូវ១៨០) សង្កាត់បឹងរាំង ខណ្ឌដូនពេញ ភ្នំពេញ
ប្រអប់សំបុត្រ ១៥៨៧
ទូរស័ព្ទ: ០២៣ ២២០ ២៣៧
ទូរសារ: ០២៣ ២១៣ ៦៥៨

**ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស (CDP)**
ផ្ទះលេខ ៥៥៧ ផ្លូវ៤៥០ សង្កាត់ទួលទំពូង២ ភ្នំពេញ
ទូរស័ព្ទនិងទូរសារ: ០២៣ ២១៤ ០២៩/ ២១៤ ០១៩/ ០១២ ៩០១ ១៩៩
សារអេឡិចត្រូនិក: cdp@cdpcambodia.org
គេហទំព័រ: www.dcpcambodia.org

**សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)**
ផ្ទះលេខ ៣ ផ្លូវលេខ ១៥៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទនិងទូរសារ: ០២៣ ៩៩០ ៥៤៤
សារអេឡិចត្រូនិក: adhoc@forum.org.kh
គេហទំព័រ: www.adhoc-cambodia.org

**ជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)**
ផ្ទះលេខ ៥១ ផ្លូវលេខ ៦០៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក ភ្នំពេញ
ប្រអប់សំបុត្រលេខ ១១៦៧
ទូរស័ព្ទ: ០២៣ ៨៨៣ ៩១៤ / ៨៨៣ ៩២៤
ទូរសារ: ០២៣ ៨៨០ ៩១៤
សារអេឡិចត្រូនិក: lac@online.com.kh

គេហទំព័រ: www.lac.org.kh.english/

## អង្គការពិគ្រោះយោបល់ និងផ្តល់សេវាសុខភាពផ្លូវចិត្ត

### អង្គការចិត្តសង្គម-អន្តរវប្បធម៌ (TPO)

ផ្ទះលេខ២ & ៤ កាច់ជ្រុងផ្លូវហាណូយ &
ផ្លូវឧកញ៉ាវាំង ភ្នំពេញថ្មី ភ្នំពេញ
ប្រអប់សំបុត្រលេខ: ១១២៤
លេខទូរស័ព្ទ: ០២៣ ៦៣៦ ៦៩ ៩១ / ៦៣៦ ៦៩ ៩២ / ៦៣៦ ៦៩ ៩៣
សារអេឡិចត្រូនិក: admin@tpocambodia.org
គេហទំព័រ: www.tpocambodia.org

### អង្គការចិត្តសង្គម-អន្តរវប្បធម៌ ខេត្តបាត់ដំបង

ភូមិរំចេក៤ ឃុំរតនៈ ក្រុងបាត់ដំបង
លេខទូរស័ព្ទ: ០៥៣ ៦៣៣ ៣៦ ១១
សារអេឡិចត្រូនិក: tpobtb@tpocambodia.org

### អង្គការចិត្តសង្គម-អន្តរវប្បធម៌ ខេត្តសៀមរាប

ផ្ទះលេខ ១៣៨ ភូមិមណ្ឌល ៣ ឃុំស្លក្រាម
លេខទូរស័ព្ទ: ០៦៣ ៦៣៣ ៣៦ ១១
សារអេឡិចត្រូនិក: srgiz@tpocambodia.org

### អង្គការចិត្តសង្គម-អន្តរវប្បធម៌ ខេត្តបន្ទាយមានជ័យ

ផ្ទះលេខ ១៨ ផ្លូវលេខ ៤ ក្រុម ២៨ ភូមិសូភី
ឃុំកំពង់ស្វាយ ក្រុងសិរីសោភ័ណ
លេខទូរស័ព្ទ: ០៥៤ ៦៥២ ០៦ ៦៦
សារអេឡិចត្រូនិក: tpobmc@tpocambodia.org

### អង្គការចិត្តសង្គម-អន្តរវប្បធម៌ ខេត្តកំពង់ធំ

ផ្ទះលេខ៣៦ ភូមិទី៧ ឃុំកំពង់ធំ ស្រុកស្ទឹងសែន
លេខទូរស័ព្ទ: ០៦២ ៩៦១ ៣៧៥
សារអេឡិចត្រូនិក: tpokgthom@tpocambodia.org / kgthomgiz@tpocambodia.org

### សេវាសង្គមកិច្ចកម្ពុជា (សសក) ក្រុងភ្នំពេញ

ស្ថិតក្នុងវិទ្យាស្ថានជាតិសុខភាពសាធារណៈ:
ផ្ទះលេខ ២ ផ្លូវ ២៨៩ (ផ្លូវគីមអ៊ីលស៊ុង) ភ្នំពេញ
ប្រអប់សំបុត្រលេខ: ១៤៧៧
ទូរស័ព្ទ: ០២៣ ៨៨១ ៤៣២ / ០២៣ ៨៨១ ៥៣២
ទូរស័ព្ទដៃ: ០១២ ៨១១ ៨២៥
ទូរសារ: ០២៣ ៨៨១ ៤៣០
សារអេឡិចត្រូនិក: ssc@online.com.kh

### សេវាសង្គមកិច្ចកម្ពុជា (សសក) ខេត្តកំពង់ស្ពឺ

ផ្លូវជាតិលេខ ៤ ភូមិត្នុំដី ឃុំព្រៃស្លឹក ស្រុកច្បារមន
(ចម្ងាយ ៣ គីឡូម៉ែត្រ ខាងលិចផ្សារកំពង់ស្ពឺ)
លោកស្រី ហេង ស្រី ទូរស័ព្ទ: ០១២ ៨០៣ ៥៣៣

## សេវាសុខភាពផ្លូវចិត្តរបស់រាជរដ្ឋាភិបាល

**ខេត្តបន្ទាយមានជ័យ** : មន្ទីរពេទ្យមង្គលបូរី
ភូមិកោះកែវ ឃុំឫស្សីក្រោក
វេជ្ជ. វ៉ាន់ លុច: ០១២ ៦០០ ៣២១
លោក ហូ សេរីវិទូ (ប្រធានមន្ទីរពេទ្យ)

**ខេត្តបាត់ដំបង** : មន្ទីរពេទ្យបង្អែកបាត់ដំបង
ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង
វេជ្ជ. អ៊ុំ ញិល: ០១២ ៨៨៩ ៨៩៧

**ខេត្តកំពង់ចាម** : មន្ទីរពេទ្យបង្អែកកំពង់ចាម
ភូមិ ទី៧ ឃុំកំពង់ចាម ស្រុកកំពង់ចាម
លោក ស សាវុធ: ០១២ ៨៩២ ០៩២

**ខេត្តកំពង់ស្ពឺ** : មន្ទីរពេទ្យបង្អែកឧដុង្គ
ភូមិពន្លៃ ឃុំវាំងចាស់ ស្រុកឧដុង្គ
លោក គឹម សុភាព: ០១២ ៩១០ ០៦២

**ខេត្តកំពង់ធំ** : មន្ទីរពេទ្យបង្អែកកំពង់ធំ
ឃុំកំពង់ធំ ស្រុកស្ទឹងសែន
វេជ្ជ. អ៊ិត ប៊ុនគី : ០១១ ៨៦៤ ៨៨៧

**ខេត្តកំពត** : មន្ទីរពេទ្យបង្អែក
លោកស្រី ចាប សុជាតា : ០១២ ៧០០ ១៦៧

**ខេត្តកណ្តាល** : មន្ទីរពេទ្យជ័យជំនះ
មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ
ផ្ទះលេខ ៤៧ ផ្លូវ ១៩៨ ក្រុងតាខ្មៅ
លេខទូរស័ព្ទ: ០២៣ ៣០០ ៥៣៤/៩៨៣ ៣៤៨
វេជ្ជ.ភូមី កុមារ : ០១២ ៤៨២ ៨៥៤

**រាជធានីភ្នំពេញ** : មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត
ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត
វេជ្ជ. ការ ស៊ុនបូណាត : ០១២ ៨៦៥ ៤៤០
វេជ្ជ. អាង សូឌី : ០១២ ៦២២ ៤៨៧

**ខេត្តព្រះវិហារ** : មន្ទីរពេទ្យបង្អែកព្រះវិហារ
ភូមិឡូតដ្ឋ  ឃុំកំពង់ត្រណាក់ ស្រុកត្បែងមានជ័យ
វេជ្ជ. ជូ ប៉ូលីណា : ០១២ ៩៦៨ ៣២៨

**ខេត្តពោធិ៍សាត់** : មន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់
ឃុំផ្ទាក់ព្រៃ ស្រុកសំពៅមាស
វេជ្ជ. តេង ហុកលី : ០១២ ៩៨៩ ៣០៦

**ខេត្តសៀមរាប** : មន្ទីរពេទ្យបង្អែក
ភូមិមណ្ឌល ១ ឃុំស្វាយដង្គុំ ស្រុកសៀមរាប
លោក មុំ សុវណ្ណារ៉ា : ០១២ ៧០០ ៨៩៩

**ខេត្តស្វាយរៀង** : មន្ទីរពេទ្យបង្អែក
ភូមិស្រះវង់ ឃុំស្វាយរៀង ស្រុកស្វាយរៀង
វេជ្ជ. សូ បូរាណ : ០១១ ៦៣៨៣០៧

## សមាគមជនរងគ្រោះ

### សមាគមជនរងគ្រោះដោយរបបខ្មែរក្រហម ក្នុងប្រទេសកម្ពុជា
សារអេឡិចត្រូនិក: president@akrvc.org

### សមាគមក្សេមក្សាន្ត
លេខទូរសព្ទ៍: ០១២ ៧១២ ១៤៨
សារអេឡិចត្រូនិក: info@ksemksan.org








អង្គការសហប្រជាជាតិ
UNITED NATIONS
ORGANISATION DES NATIONS UNIES
E.C.C.C * C.E.T.C
ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ROYAUME DU CAMBODGE







# ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្ដីមេដឹកនាំខ្មែរក្រហម

ការបោះពុម្ពលើកទី ១ នៅខែសីហា ឆ្នាំ២០០៤ ដោយក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការបង្កើតសាលាក្ដីខ្មែរក្រហម ការិយាល័យទីស្ដីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
កូនសៀវភៅនេះត្រូវបានកែសម្រួលនិងបន្ថែមព័ត៌មានមួយចំនួនក្នុងការបោះពុម្ពលើកទី ៥ ដោយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក
ការបោះពុម្ពផ្សាយឡើងវិញទាំងស្រុងឬដោយផ្នែកនៃកូនសៀវភៅនេះ ត្រូវបានអនុញ្ញាតនិងលើកទឹកចិត្ត ប៉ុន្តែត្រូវមានការបញ្ជាក់ពីប្រភព

## ដំណើរឆ្ពោះទៅមុខប្រកបដោយភាពយុត្តិធម៌

ផ្នែកកិច្ចការសាធារណៈ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ : +៨៥៥ (0) ២៣ ៨៦១ ៥00 ទូរសារ : +៨៥៥ (0) ២៣ ៨៦១ ៥៥៥
សារអេឡិចត្រូនិច : pas@eccc.gov.kh
គេហទំព័រ : www.eccc.gov.kh

អ.វ.ត.ក ក្នុងបណ្ដាញទំនាក់ទំនងសង្គម : www.facebook.com/krtribunal
www.flickr.com/krtribunal
www.youtube.com/krtribunal
www.twitter.com/krtribunal